**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥

*«ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព»*

**បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា**

**នាថ្ងៃពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២**

**ត្រូវនឹងថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៩**

# បុព្វកថា

ក្នុងនាមជាប្រមុខរាជរដ្ឋាភិបាល ខ្ញុំសូមគូសបញ្ជាក់ប្រកបដោយមោទនភាពជាថ្មីម្តងទៀតថា កត្តាសុខសន្តិភាព និងស្ថិរភាពនយោបាយ ដែលបាននិងកំពុងកើតមាននៅទូទាំងប្រទេសបានហុចលទ្ធផលជាផ្លែផ្កាឱ្យកម្ពុជាទទួលបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ គ្មានពេលណាដែលសម្ពាធថវិកា ក៏ដូចជាហិរញ្ញវត្ថុសាធារណៈរបស់យើងមានសភាពធូរស្រាលដូចក្នុងពេលបច្ចុប្បន្នឡើយ។ ស្ថានភាពអំណោយផលបែបនេះ បានបង្កើតកាលានុវត្តភាព និងលទ្ធភាព ឱ្យរាជរដ្ឋាភិបាលបោះជំហានកាន់តែស្វាហាប់ក្នុងការកែទម្រង់លើគ្រប់វិស័យ ពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឈានទៅសម្រេចគោលដៅនៃចក្ខុវិស័យឆ្នាំ២០៣០ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសចំណូលខ្ពស់។

ជាបទពិសោធន៍នៅគ្រប់ការដ្ឋានកែទម្រង់ទាំងអស់ *«គ្មានសមិទ្ធផលណាដែលបានមកដោយពុំមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណា ដែលសម្រេចបានដោយពុំមានការលះបង់នោះដែរ»*។ នេះគឺជាកត្តាសត្យានុម័តដែលរាជរដ្ឋាភិបាលពិតជាគ្មានជម្រើសអ្វីផ្សេង ក្រៅពីធ្វើការកែទម្រង់តាមទិសស្លោកដែលខ្ញុំតែងតែរំលឹកថា *«កែទម្រង់ គឺរស់, មិនកែទម្រង់ គឺស្លាប់»*។ ក្នុងន័យនេះ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានសម្រេច និងអនុម័ត *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»* ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨។ ឯកសារយុទ្ធសាស្ត្រនេះ បានចង្អុលបង្ហាញឲ្យរៀបចំ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* ដើម្បីប្រែក្លាយជាប្រព័ន្ធថវិកាជាតិពេញលេញ និងតែមួយ។

*«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* បានបង្ហាញឱ្យឃើញពីការបោះជំហានថ្មីមួយទៀត និងជាសក្ខីកម្មនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានសាធារណៈ។ ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មិនគ្រាន់តែជាការផ្លាស់ប្តូររបៀបរបបនៃការគ្រប់គ្រងថវិកាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ ដែលជាសមាសធាតុដ៏សំខាន់មួយដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ២០១៨-២០២៥។ កិច្ចការនេះ ចាំបាច់ត្រូវអនុវត្តដោយសកម្ម ប្រាកដនិយម ប្រយ័ត្នប្រយែង និងសន្សឹមៗ ដោយឈរលើតថភាពជាក់ស្តែងនៃកម្ពុជា។

ខ្ញុំចង់គូសបញ្ជាក់ថា *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* គឺជាចំណុចចាប់ផ្តើមនៃដំណើរវែងឆ្ងាយបន្តទៀត នៅក្នុងការប្រែក្លាយប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិកម្ពុជាឱ្យក្លាយជាប្រព័ន្ធមួយដែលមាន*ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព* ឆ្ពោះទៅសម្រេចគោលដៅឆ្នាំ២០២៥។ អាស្រ័យហេតុនេះ, ការចូលរួមប្រកបដោយ បុរេសកម្ម និងសកម្មរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ គឺជាកត្តាមិនអាចខ្វះបាន ដើម្បីធានាបានជោគជ័យបន្តទៀតនៅក្នុងការងារដោយប្រកាន់ខ្ជាប់នូវគោលការណ៍

និងស្មារតីភ្ញាក់រលឹកធ្វើការកែទម្រង់ជាប្រចាំ ឬការកែលម្អការងារជាប្រចាំតាមអភិក្រម «*ងូតទឹក ឆ្លុះកញ្ចក់ ដុសក្អែល និងព្យាបាល*» ។

ជាចុងក្រោយ, ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និងសូមថ្លែងអំណរគុណដល់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងឯកឧត្តម លោកជំទាវជារដ្ឋមន្ត្រី និងប្រធានស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលខិតខំប្រឹងប្រែងក្នុងការដឹកនាំ និងសហការអនុវត្តការងារកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយឆន្ទៈក្លៀវក្លា និងស្មារតីនៃភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ រហូតសម្រេចបានជោគជ័យគួរជាទីមោទនៈ។ ខ្ញុំសូមប្រសិទ្ធពរឱ្យសុឆន្ទៈ ភាពជាម្ចាស់ ការទទួលខុសត្រូវ កិច្ចខិតខំប្រឹងប្រែង និងការរួមចំណែក ព្រមទាំងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងភាគីពាក់ព័ន្ធ កាន់តែរីកដុះដាលរឹងមាំឡើងជាលំដាប់ថែមទៀត ដើម្បីធានាជំរុញអនុវត្ត *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* សម្រេចបានជោគជ័យតាមការរំពឹងទុក។

*ថ្ងៃ ពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តែងតែយកចិត្តទុកដាក់ និងកំណត់ទុកការងារកែទម្រង់ គឺជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា និងបង្កើតកាលានុវត្តភាពថ្មីៗ ឆ្ពោះទៅរកការអភិវឌ្ឍ និងវិបុលភាព។ ការងារកែទម្រង់ដ៏មានសារសំខាន់បី ដែលកំពុងបន្តតួនាទីជាសសរស្តម្ភសម្រាប់ធានាជោគជ័យនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នេះ គឺការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃក្របខ័ណ្ឌគោលនយោបាយ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈនៃការផ្ទេរសិទ្ធិអំណាច មុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង និងចាត់ចែង ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ បានទាន់ពេលវេលា ប្រកបដោយគុណភាព ប្រសិទ្ធភាព និងគណនេយ្យភាព។ រាជរដ្ឋាភិបាលបានដាក់ឲ្យអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រយៈពេលមធ្យម និងវែង ដោយបានបង្កើនប្រភពធនធានថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈការបង្កើត និងដាក់ឲ្យអនុវត្តនូវយន្តការសំខាន់ៗមួយចំនួន ដូចជា ការបង្កើនអត្រាវិភាជប្រចាំឆ្នាំដល់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់, ការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់, ការបង្កើនការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងការអនុវត្តយន្តការនៃការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័នទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមគ្នានឹងយន្តការនៃការបែងចែក និងប្រើប្រាស់ធនធានសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹង។ ការកែទម្រង់ប្រព័ន្ធរដ្ឋបាលសាធារណៈ ក៏កំពុងតែមានដំណើរការទៅមុខផងដែរ។

នៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ជាពិសេសសម្រេចបានជាសារវ័ន្តនូវជំហានទី១ គឺ *«ភាពជឿទុកចិត្តនៃថវិកា»* និងជំហានទី២ គឺ *«គណនេយ្យភាពហិរញ្ញវត្ថុ»*។ បច្ចុប្បន្ននេះ ការអនុវត្តជំហានទី៣ គឺ *«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»* ក៏កំពុងមានវឌ្ឍនភាពល្អ ដោយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២០ មុននឹងឈានទៅអនុវត្តជំហានទី៤ គឺ *«គណនេយ្យភាពសមិទ្ធកម្ម»* ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ ក្នុងក្របខ័ណ្ឌនៃការកំពុងអនុវត្តជំហានទី៣ និងការត្រៀមលក្ខណៈសម្រាប់អនុវត្តជំហានទី៤, ឯកសារ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»*, ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ត្រូវបានរៀបចំតាក់តែងឡើង និងដាក់ឱ្យគណៈរដ្ឋមន្ត្រីអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨។ ឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ បានចង្អុលបង្ហាញយ៉ាងច្បាស់ពីអភិក្រមនៃការផ្លាស់ប្តូរប្រព័ន្ធថវិការបស់កម្ពុជាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅ

ដើម្បីធ្វើឱ្យការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈកាន់តែប្រសើរឡើង និងស្របតាមគោលដៅជាសារវន្ត ដើម្បីឈានឆ្ពោះទៅអនុវត្ត *«ថវិកាព័ត៌មានសមិទ្ធកម្ម»* ស្របតាមទិសដៅជាយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្មឆ្នាំ២០២៥។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥* នេះ ក៏បានផ្តល់នូវក្របខ័ណ្ឌទស្សនាទានសម្រាប់តម្រង់ទិសក្នុងការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ឯកសារយុទ្ធសាស្ត្រនេះបានកំណត់ថា ប្រទេសកម្ពុជាមានប្រព័ន្ធថវិកាតែមួយប៉ុណ្ណោះគឺ *«ប្រព័ន្ធថវិកាជាតិ»* ដោយប្រព័ន្ធថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិស្ថិតនៅក្នុងនោះមានលក្ខណៈជាអនុប្រព័ន្ធ។ ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ មានលក្ខណៈដូចគ្នាទៅនឹងប្រព័ន្ធថវិកាជាតិដែរ ប៉ុន្តែមានលក្ខណៈសាមញ្ញ ទន់ភ្លន់ ហើយជាគោលការណ៍ ការវិភាជ និងការអនុវត្តថវិកាត្រូវបានផ្តល់ឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

តាមទិសដៅនេះ ខ្ញុំបានចាត់តាំងក្រុមការងារមួយ ដែលស្ថិតនៅក្រោមការដឹកនាំកម្រិតគោលនយោបាយដោយ **ឯកឧត្តមរដ្ឋលេខាធិការ ជូ គឹមឡេង** និង **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល កែវ ចេងឧត្តម៍** និងកម្រិតបច្ចេកទេសដោយ **បណ្ឌិត ឌី សុវណ្ណា** ឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែង គឺ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* ស្របតាមបរិការណ៍បច្ចុប្បន្ននៃកម្ពុជា។

ដើម្បីធានាបានភាពគ្រប់ជ្រុងជ្រោយ, ឯកសារ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* ត្រូវបានរៀបចំដោយបានឆ្លងកាត់ការសិក្សា និងដកស្រង់បទពិសោធន៍ពីប្រទេសមួយចំនួន, បទពិសោធន៍នៃការអនុវត្តការងារជាក់ស្តែង, ការផ្តល់មតិយោបល់ពីដៃគូអភិវឌ្ឍន៍សំខាន់ៗ, ព្រមទាំងបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនលើកច្រើនសារនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រដ្ឋបាលថ្នាក់ក្រោមជាតិ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេស ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥* គឺជាឯកសារតម្រង់ទិសដែលបានកំណត់អំពីទិសដៅ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ និងបានដាក់ចេញផែនការសកម្មភាពកែទម្រង់ដែលមានសង្គតិភាពជាមួយនឹងប្រព័ន្ធថវិកាជាតិ តាមអភិក្រម **សាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព** ស្របទៅតាមសមត្ថភាព និងបរិការណ៍ជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រនេះ ក៏បានកំណត់គោលបំណង និងគូសវាសផ្លូវនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដោយធ្វើការពន្លឿន និងកែសម្រួលនីតិវិធីលទ្ធកម្មសាធារណៈ តាមអភិក្រមជាជំហានៗ និងមានសង្គតិភាពជាមួយទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥* មានទិសដៅពង្រឹង និងពង្រីកការអនុវត្ត *«ថវិកាកម្មវិធី»* ជាបណ្តើរៗ ដើម្បីធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសគោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ។

រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីប្រភេទ នឹងត្រូវធ្វើការគ្រោងផែនការសកម្មភាពមានលក្ខណៈប្រមូលផ្ដុំ ដើម្បីតម្រង់ទិស បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ជាងមុន សម្រាប់ជាមូលដ្ឋានក្នុងការតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត។ ធ្វើការកែលម្អ និងផ្លាស់ប្ដូរជាជំហានៗវដ្ដថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្ដថវិកាជាតិ ពិសេស កំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្ដថវិកាដែលរួមទាំងការធ្វើស្ថាប័ននីយកម្មជាបណ្ដើរៗនៃរបបរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ។

ទន្ទឹមនឹងនេះ ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើការកែលម្អ ដោយប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជាបណ្ដើរៗបន្ថែមទៀតជូនរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់នៅឆ្នាំ២០២៥។ ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ នឹងត្រូវពង្រឹងជាបណ្ដើរៗតាមរយៈការធ្វើសវនកម្មកិច្ចលទ្ធកម្ម។

ខ្ញុំសូមសំដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមជាមតិយោបល់ និងអនុសាសន៍នានារបស់អ្នកពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានសម្របសម្រួល និងរៀបចំតាក់តែងឯកសារនេះប្រកបដោយភាពវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ឯកសារ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»* នឹងត្រូវបានប្រើប្រាស់ជាឯកសារមគ្គុទេសក៍សម្រាប់រៀបចំប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលឆ្លើយតបបានទៅនឹងការបង្កើន *«សេវាសាធារណៈ បរិយាប័ន្ន និងតម្លៃនៃលុយ»* ព្រមទាំងសម្រាប់ជាប្រយោជន៍ដល់សាធារណជនទូទៅបានសិក្សាស្រាវជ្រាវ។

ជាទីបញ្ចប់, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យឈានទៅសម្រេចឱ្យបានលទ្ធផលដែលបានគ្រោងទុកនៅក្នុងដំណាក់កាលនីមួយៗ និងនៅក្នុងឆ្នាំ២០២៥ ក្នុងបុព្វហេតុសំខាន់បំផុតគឺ កសាងប្រព័ន្ធថវិកាមួយដែលមានប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពស្របតាមសមត្ថភាព និងតថភាពជាក់ស្ដែងនៃរដ្ឋបាលថ្នាក់ក្រោមជាតិកម្ពុជា។

*ថ្ងៃ[illegible] ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


**បុព្វកថា** i-ii

**អារម្ភកថា** I-III

**១. សេចក្តីផ្តើម** ១

**២. ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** ៦

២.១ ការគ្រប់គ្រងរដ្ឋបាលសាធារណៈ ៦

២.២ ការគ្រប់គ្រងបុគ្គលិក និងការកសាងសមត្ថភាព ៧

២.៣ ការគ្រប់គ្រងសេវារដ្ឋបាល និងសេវាសាធារណៈ ៨

២.៤ ការគ្រប់គ្រងថវិកា ៩

២.៥ កិច្ចលទ្ធកម្ម ១២

២.៦ ច្បាប់, បទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការគ្រប់គ្រងថវិកា ១៣

**៣. ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ** ១៤

៣.១. ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ ១៤

៣.២. ការត្រួតពិនិត្យមើលលើការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ១៥

៣.៣. ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ១៦

៣.៤. ទិសដៅ និងក្របខ័ណ្ឌពេលវេលានៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ១៨

**៤. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥** ២០

៤.១. វដ្តថវិកា ២០

៤.១.១. ការធ្វើផែនការយុទ្ធសាស្ត្រថវិកា ២០

៤.១.២. ដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ២៣

៤.១.៣. ការចរចារថវិកា និងការអនុម័តថវិកា ២៥

៤.១.៤. ការអនុវត្ត និងការត្រួតពិនិត្យថវិកា ២៨

៤.១.៥. ប្រព័ន្ធរបាយការណ៍, ការតាមដាន, និងការវាយតម្លៃថវិកា ៣២

៤.២. ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ៣៤

៤.២.១. ក្របខ័ណ្ឌគតិយុត្តិនៃថវិកា ៣៤

៤.២.២. ការកសាង និងអភិវឌ្ឍសមត្ថភាព ៣៥

៤.២.៣. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣៥

**៥. សេចក្តីសន្និដ្ឋាន** ៣៦

*ឧបសម្ព័ន្ធ÷ ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រ ២០២៥*

# ១. សេចក្តីផ្តើម

ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាផ្នែកមួយដ៏សំខាន់នៃក្របខ័ណ្ឌគោលនយោបាយ ដែលចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ តាមរយៈ *«ការផ្តល់សេវាសាធារណៈ»* ឱ្យកាន់តែមានប្រសិទ្ធភាពដល់ប្រជាពលរដ្ឋ។ មូលដ្ឋានដ៏សំខាន់សម្រាប់ការអនុវត្តកំណែទម្រង់នេះ រួមមាន ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១, ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឆ្នាំ២០០៥, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឆ្នាំ២០០៨ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩។ ច្បាប់ និងក្របខ័ណ្ឌយុទ្ធសាស្ត្រទាំងនេះបានផ្តល់គោលការណ៍ណែនាំ និងផ្តល់ជាផែនទីបង្ហាញផ្លូវក្នុងការផ្ទេរធនធាន និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឆ្នាំ២០០៨ បានផ្តល់ជាក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងគោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍ *«រដ្ឋបាលឯកភាព»* ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈការកំណត់តួនាទី មុខងារ និងសិទ្ធិអំណាចទៅតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

សមិទ្ធផលជាគន្លឹះដែលសម្រេចបានពីកំណែទម្រង់នេះ គឺមូលដ្ឋានគ្រឹះនៃប្រព័ន្ធគ្រប់គ្រងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត និងដាក់ឱ្យអនុវត្តនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងនោះរួមមាន បែបបទនិងនីតិវិធីបំពេញការងារ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធទំនាក់ទំនងការងារលក្ខណៈអន្តររដ្ឋបាល យន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយ យន្តការទទួលនិងដោះស្រាយបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងរបាយការណ៍ជាដើម កំពុងត្រូវបានអនុវត្ត និងកែលម្អជាបណ្តើរៗ។ យុទ្ធសាស្ត្រពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក៏កំពុងត្រូវបានបញ្ជ្រាបឱ្យកាន់តែស៊ីជម្រៅទៅក្នុងរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្របខ័ណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានដាក់ឱ្យអនុវត្ត ដែលក្នុងនោះមុខងារមួយចំនួនក៏ត្រូវបានផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងក្នុងបែបផែននៃការប្រគល់ និងការធ្វើប្រតិភូកម្មក្នុងលក្ខណៈជាការអនុវត្តសាកល្បងផងដែរ។ ក្នុងក្របខ័ណ្ឌនៃវិមជ្ឈការហិរញ្ញវត្ថុ, មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកត្រូវបានបង្កើត និងបង្កើនទំហំជាបន្តបន្ទាប់ ផ្អែកតាមកំណើនចំណូលចរន្តនៃថវិកាជាតិ។ ក្រៅពីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់នឹងទទួល

បាននូវធនធានកាន់តែច្រើនបន្ថែមទៀតពីចំណូលចែករំលែកសារពើពន្ធ និងមិនមែនសារពើពន្ធពីរដ្ឋបាលរាជធានី ខេត្ត និងពីមូលនិធិវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែក សកម្មភាពជាច្រើននៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានអនុវត្តដោយផ្អែកតាមតម្រូវការជាក់ស្តែង ដើម្បីគាំទ្រដល់ការវិវឌ្ឍផ្លាស់ប្តូរនៃកិច្ចដំណើរការកំណែទម្រង់នេះ។

ទោះបីជាសម្រេចបាននូវសមិទ្ធផលជាគន្លឹះៗយ៉ាងនេះក្តី ក៏នៅមានភាពស្មុគស្មាញ ដោយសារតែកំណែទម្រង់នេះមានលក្ខណៈអន្តរវិស័យដែលមានការពាក់ព័ន្ធទៅនឹងស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានចរិតលក្ខណៈខុសៗគ្នា ព្រមទាំងមានកិច្ចការជាអាទិភាពជាច្រើនផ្សេងទៀតដែលត្រូវបន្តអនុវត្ត ជាពិសេសលើការពង្រឹងអភិបាលនុក្រម និងសមត្ថភាពស្ថាប័ន។

ទន្ទឹមនឹងមានការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលដឹកនាំ និងសម្របសម្រួលដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) និង**ការកែទម្រង់រដ្ឋបាលសាធារណៈ** ដែលដឹកនាំ និងសម្របសម្រួលដោយក្រសួងមុខងារសាធារណៈ ក៏មានការកែទម្រង់ដ៏សំខាន់មួយទៀតគឺ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្តជាផ្លូវការនៅឆ្នាំ២០០៤ គឺជាកម្មវិធីកំណែទម្រង់រយៈពេលវែង ដោយបានកំណត់គោលដៅច្បាស់លាស់ក្នុងការប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឱ្យទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងកម្រិតឧត្តមានុវត្តន៍ និងស្តង់ដារអន្តរជាតិនៅឆ្នាំ២០២៥។ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តខាងលើនេះ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់យកនូវ *«អភិក្រមជាខឿន»* ពោលគឺ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលត្រូវបានចែកចេញជាដំណាក់កាលៗ និងជាជំហានៗ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ដំណាក់កាលទី១ (២០០៥-២០០៨) គឺការកសាងបាននូវ *«ភាពជឿទុកចិត្តនៃថវិកា»* ដោយបានផ្លាស់ប្តូរស្ថានភាពនៃ *«ការខ្វះសាច់ប្រាក់ជុំរ៉ាំរ៉ៃ»* មកជា *«អតិរេកសាច់ប្រាក់»* ព្រមទាំងកសាងបាននូវគ្រឹះដ៏រឹងមាំសម្រាប់ឈានទៅអនុវត្តដំណាក់កាលទី២ជាបន្តទៀត។ ដំណាក់កាលទី២ (២០០៩-២០១៥) គឺការកែលម្អនីតិវិធីអនុវត្តថវិកា ការបង្កើតមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី និងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាឧបករណ៍ដ៏មានសារៈសំខាន់សម្រាប់ *«ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ»*។ ការអនុវត្តនៃផែនការសកម្មភាពដំណាក់កាលទី២ គឺការកសាងជាគ្រឹះសម្រាប់ឈានទៅអនុវត្តដំណាក់កាលទី៣ (២០១៦-២០២០) ដែលមានគោលដៅជាសារវ័ន្តគឺ *«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»*។ ទន្ទឹមនឹងបន្តអនុវត្ត និងពង្រឹងផែនការសកម្មភាពការងារដែលបានដាក់ចេញក្នុងដំណាក់កាលទី១ និងទី២ វាក៏ជាដំណាក់កាលនៃការគិតគូរផ្លាស់ប្តូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាដែលមានលក្ខណៈមជ្ឈការ និងផ្អែកលើធាតុចូលទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ។ ដំណាក់កាលទី៤ (២០២១-២០២៥) គឺការបង្កើន

*«គណនេយ្យភាពសមិទ្ធកម្ម»* ដែលរាប់បញ្ចូលនូវក្របខ័ណ្ឌថវិកាសមិទ្ធកម្ម ការកំណត់បន្ទាត់គណនេយ្យភាពថវិកាសមិទ្ធកម្ម ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌសវនកម្មសមិទ្ធកម្ម និងផែនការអភិវឌ្ឍន៍សមត្ថភាព។

សម្រាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ទទួលបានការឧបត្ថម្ភធនឬការផ្ទេរធនធានថវិកាពីថ្នាក់ជាតិ។ បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ ទទួលបានការផ្តល់ហិរញ្ញប្បទានស្ទើរតែទាំងស្រុងដោយការផ្ទេរថវិកាពីថ្នាក់ជាតិ។ ថវិការដ្ឋបាលរាជធានី ខេត្ត មានប្រភពចំណូលពីមូលដ្ឋាន (ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ) និងការផ្ទេរថវិកាពីថ្នាក់ជាតិ។ ទន្ទឹមនឹងនេះ ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ តាមរយៈយន្តការនៃការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងមានដំណើរការទៅមុខ ដោយបានដាក់ឱ្យអនុវត្តតាមអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពី *«ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ»* ដែលអនុក្រឹត្យនេះបានផ្តល់នូវយន្តការសម្របសម្រួល និងគ្រប់គ្រងហានិភ័យនៃការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារទៅអាជ្ញាធរថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌមួយទៀត តាមរយៈអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពី *«ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ»* ដែលមូលនិធិនេះ មានគោលដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តល់ហិរញ្ញប្បទានទៅដល់គម្រោងវិនិយោគសាធារណៈដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការបំពេញភារកិច្ច និងការគ្រប់គ្រងការវិនិយោគសាធារណៈ។ ដូចគ្នានឹងការកែទម្រង់វិសហមជ្ឈការដែរ ការផ្ទេរមុខងារតែងតែមានហានិភ័យ ព្រោះថាការផ្តល់សេវាសាធារណៈនឹងកាន់តែមិនល្អប្រសិនបើមិនមានថវិកាសមស្រប និងខ្វះសមត្ថភាព ទាំងក្នុងកម្រិតស្ថាប័ន និងក្នុងកម្រិតធនធាន ហើយប្រការនេះនឹងជះឥទ្ធិពលទៅលើគុណភាពនៃរដ្ឋបាលទាំងមូល។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដែលឆ្លើយតបទៅនឹងតម្រូវការ និងសំណូមពរនៃការអភិវឌ្ឍនៅនឹងមូលដ្ឋាន។ នៅក្នុងផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គោលបំណងរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺការបង្កើនចំណាយកាន់តែច្រើនឡើងៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ទៅនឹងការកសាងសមត្ថភាព និងក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់។ នៅឆ្នាំ២០១៩ ថវិកាថ្នាក់ក្រោមជាតិមានប្រមាណ ២% នៃផ.ស.ស ដែលទំហំថវិកានេះនឹងមានការកើនឡើងជាបណ្តើរៗជារៀងរាល់ឆ្នាំទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកំពុងជំរុញការអនុវត្តយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការចាំបាច់ ដើម្បីពង្រឹងការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ធានាសមធម៌ និងប្រសិទ្ធភាពនៃការវិភាជថវិកា ដែលផ្អែកលើមូលដ្ឋានច្បាស់លាស់ និងទិសដៅត្រឹមត្រូវ ដោយប្រើប្រាស់ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីជាឧបករណ៍។ នៅពេលក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយត្រូវបានដាក់ឱ្យអនុវត្ត នោះនឹងមិនត្រឹមតែទប់ស្កាត់បាននូវហានិភ័យក្នុងកិច្ចការកែទម្រង់ប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ លើសពីនេះ ការអនុវត្ត

ថវិកាចាំបាច់ត្រូវការកែលម្អ ដោយធ្វើសាមញ្ញកម្មទាំងនីតិវិធីចំណាយ កិច្ចបញ្ជិការគណនេយ្យ និងប្រព័ន្ធតាមដាន និងត្រួតពិនិត្យ។

នៅឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានដាក់ចេញឯកសារទស្សនាទានស្តីពី *«ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០»* ដែលបានកំណត់គោលបំណងនៃការផ្លាស់ប្តូរជាបណ្តើរៗ និងជំហានៗពី *«ប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ»* ទៅរក *«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ»* ត្រឹមឆ្នាំ២០២០។ ដោយផ្អែកតាមទស្សនាទាននេះ ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយត្រូវបានចាប់ផ្តើមអនុវត្តជាបណ្តើរៗ តាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីសម្រាប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ ជាក់ស្តែង ឯកសារ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»* ដែលជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំតាក់តែងឡើង និងដាក់ឱ្យគណៈរដ្ឋមន្ត្រីអនុម័ត កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨។ ឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះបានចង្អុលបង្ហាញយ៉ាងច្បាស់ពីអភិក្រម និងផែនទីបង្ហាញផ្លូវសម្រាប់ផ្លាស់ប្តូរប្រព័ន្ធថវិការបស់កម្ពុជាទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅដើម្បីធ្វើឱ្យការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈកាន់តែប្រសើរឡើង និងស្របតាមគោលដៅជាសារវន្ត ដើម្បីឈានឆ្ពោះទៅអនុវត្ត *«ថវិកាព័តិមានសមិទ្ធកម្ម»* ស្របតាមទិសដៅជាយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្មឆ្នាំ២០២៥ ។

ទោះបីជាយ៉ាងនេះក្តី ផ្អែកតាមបទពិសោធន៍ជាក់ស្តែង និងការពិនិត្យឡើងវិញនូវការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន សន្និដ្ឋានថាក្របខ័ណ្ឌពេលវេលាដើម្បីឈានឆ្ពោះទៅអនុវត្ត *«ថវិកាព័តិមានសមិទ្ធកម្ម»* នៅឆ្នាំ២០២៥ មិនទាន់សមស្របនៅក្នុងបរិការណ៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាទេ។ ការផ្លាស់ប្តូរពីប្រព័ន្ធ *«ថវិកាកម្មវិធី»* ទៅរកប្រព័ន្ធ *«ថវិកាព័តិមានសមិទ្ធកម្ម»* នឹងជួបការលំបាកទាំងសមត្ថភាព និងធនធាន។ ការអនុវត្តថវិកាកម្មវិធីមានភាពសាមញ្ញជាង អាចអនុវត្តបាន និងគ្រប់គ្រាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសជាវិភាគទានសម្រាប់ការសម្រេចបាននូវសមិទ្ធផលជាតិ។ ដូចនេះ ការអនុវត្ត *«ថវិកាព័តិមានសមិទ្ធកម្ម»* នៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើឡើងនៅក្រោយឆ្នាំ២០២៥។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥* គឺការកែទម្រង់ប្រព័ន្ធថវិកាដែលមានរយៈពេលវែង និងគ្រប់ជ្រុងជ្រោយ សម្រាប់ធ្វើការប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិតាមអភិក្រម **សាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព** ស្របតាមសមត្ថភាព និងតថភាពជាក់ស្តែងនៃកម្ពុជា។ គោលដៅនៅឆ្នាំ២០២៥ គឺការពង្រឹង និងពង្រីកការអនុវត្ត *«ថវិកាកម្មវិធី»* ជាបណ្តើរៗ ដើម្បីធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ។ ផែនការ/កម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នា និងប្រទាក់គ្នាទៅវិញទៅមក តាមរយៈការធ្វើសមាហរណកម្មផែនការនីយកម្ម (សុខដុមនីយកម្មកិច្ចដំណើរការធ្វើផែនការ)។ ដូចគ្នានេះដែរ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវរៀបចំផែនការអន្តរាគមន៍របស់ខ្លួនដោយផ្តោតជាសំខាន់លើវិស័យអាទិភាពនៅមូលដ្ឋាន ដើម្បីគាំទ្រ

ដល់អាទិភាពគោលនយោបាយរដ្ឋបាលរាជធានី ខេត្ត។ ទន្ទឹមនឹងការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា គឺការធ្វើការកែលម្អ និងផ្លាស់ប្តូរជាជំហានៗវដ្តថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ពិសេសកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកាដែលរួមទាំងការធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ។

ជារួម *យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥* នឹងត្រូវរៀបចំដោយមានវិសាលភាពគ្របដណ្តប់លើសមាសធាតុគន្លឹះនៃវដ្តថវិកា និងការកំណត់ទិសដៅឆ្នាំ២០២៥ ដោយធ្វើការបែងចែកជា ០៥ផ្នែក រួមមាន÷ ទី១-សេចក្តីផ្តើម, ទី២-ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, ទី៣-ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, ទី៤-យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ និង ទី៥-សេចក្តីសន្និដ្ឋាន។

# ២. ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ថវិកាជាតិឬថវិការដ្ឋ រួមមាន ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ។ ថវិកាថ្នាក់ក្រោមជាតិសំដៅដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ថវិកាថ្នាក់ជាតិសំដៅដល់ថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ ការគ្រប់គ្រង និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១។

ផ្នែកនេះ នឹងរៀបរាប់អំពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែលរួមមានការគ្រប់គ្រងរដ្ឋបាលសាធារណៈ ការគ្រប់គ្រងបុគ្គលិកនិងការកសាងសមត្ថភាព ការគ្រប់គ្រងសេវារដ្ឋបាលនិងសេវាសាធារណៈ ការគ្រប់គ្រងថវិកា កិច្ចលទ្ធកម្ម និងច្បាប់ បទប្បញ្ញត្តិនិងនីតិវិធីសម្រាប់ការគ្រប់គ្រងថវិកា។

## ២.១. ការគ្រប់គ្រងរដ្ឋបាលសាធារណៈ

បច្ចុប្បន្ន រចនាសម្ព័ន្ធរដ្ឋបាលសាធារណៈកម្ពុជាមានពីរកម្រិត គឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ជាតិសំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ ចំណែកឯរដ្ឋបាលថ្នាក់ក្រោមជាតិចែកជាបីប្រភេទ រួមមាន រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់។ រាជធានី ត្រូវបានបែងចែកជា ខណ្ឌ ហើយរដ្ឋបាលខណ្ឌចែកចេញជា សង្កាត់។ ខេត្ត ចែកចេញជាក្រុង និងស្រុក ខណៈដែលក្រុងត្រូវបានបែងចែកជាសង្កាត់ និងស្រុកត្រូវចែកចេញជាឃុំ។ បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាមានរាជធានី ខេត្តចំនួន២៥ ក្រុង ស្រុក ខណ្ឌចំនួន២០៣ ឃុំ សង្កាត់ចំនួន ១ ៦៤៦ និងភូមិចំនួន ១៤ ៣៨៣។ រដ្ឋបាលឃុំ សង្កាត់ត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សា និងគណៈអភិបាលនៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ចំណែកឯឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតសកលស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសស្របតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យទៅបំរើការងារជាមួយក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ប្រធានមន្ទីរជំនាញរាជធានី ខេត្ត

នៃក្រសួង ស្ថាប័ន ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីនៃក្រសួងស្ថាប័នសាមីតាមសំណើរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ទទួលខុសត្រូវក្នុងការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់របស់ខ្លួន ពិនិត្យ និងអនុម័ត។

បច្ចុប្បន្ន ការត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានប្រមូលផ្តុំតាមយន្តការត្រួតពិនិត្យជាមុនដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ លើកលែងតែថវិកាឃុំ សង្កាត់ គឺមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តថវិកាដោយផ្ទាល់។ រតនាគាររាជធានី ខេត្ត ដើរតួនាទីជាគណនេយ្យករសាធារណៈ និងទូទាត់ចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីប្រភេទ។

## ២.២. ការគ្រប់គ្រងបុគ្គលិក និងការកសាងសមត្ថភាព

ការរៀបចំ និងការគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដូចជាច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ទទួលខុសត្រូវរៀបចំផែនការបុគ្គលិកគ្រប់ប្រភេទក្របខ័ណ្ឌនៅពេលមានតម្រូវការធនធានមនុស្សដើម្បីបំពេញភារកិច្ច និងករណីកិច្ចឆ្លើយតបទៅនឹងតម្រូវការការងារដែលរដ្ឋបាលនីមួយៗត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំនីមួយៗធ្វើឡើងនៅរាល់ត្រីមាសទី១ នៃឆ្នាំ ដើម្បីដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំបន្ទាប់ ដោយមានការគាំទ្រពីមន្ទីរមុខងារសាធារណៈ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។ គោលការណ៍ បែបបទ និងនីតិវិធីនៃការរៀបចំផែនការបុគ្គលិកត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មន្ត្រីទទួលបន្ទុកភាគច្រើនមិនសូវមានជំនាញ និងមានការផ្លាស់ប្តូរជាញឹកញាប់ ដោយហេតុផលផ្សេងៗ ជាពិសេស នៅរដ្ឋបាលក្រុង ស្រុក។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានខិតខំផ្តល់ការណែនាំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការគាំទ្រពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារ រាជធានី ខេត្ត។

ទោះបីជាមានយន្តការក្នុងការពង្រឹងសមត្ថភាពតាមរយៈវគ្គបណ្តុះបណ្តាលបច្ចេកទេសដល់គ្រូបង្គោល និងមន្ត្រីជំនាញក៏ដោយ ក៏សមត្ថភាពមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ។ លើសពីនេះទៀត ការធ្វើទំនើបកម្ម ការពង្រឹងប្រព័ន្ធថវិកាតាមរយៈការដាក់ឱ្យរដ្ឋបាលរាជធានី ខេត្តរៀបចំផែនការយុទ្ធសាស្ត្រថវិកា

និងអនុវត្តថវិកាកម្មវិធី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត ទាមទារឱ្យមានការពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃតម្រូវការការងារក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

## ២.៣. ការគ្រប់គ្រងសេវារដ្ឋបាល និងសេវាសាធារណៈ

ក្នុងពេលបច្ចុប្បន្ន សេវាសាធារណៈដែលមានលក្ខណៈជា *«សេវារដ្ឋបាល»* មួយចំនួនធំត្រូវបានប្រមូលផ្តុំផ្តល់ដោយអង្គភាព ឬការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងសេវាសាធារណៈមួយចំនួនទៀតមិនទាន់ត្រូវបានផ្តល់ដោយអង្គភាព ឬការិយាល័យច្រកចេញចូលតែមួយនៅឡើយ។ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយ ដែលជាយន្តការសម្រាប់ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ត្រូវបានបង្កើតឡើងដើម្បីផ្តល់សេវារដ្ឋបាលចាំបាច់នានា ដែលបានផ្ទេរពីរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ហេតុនេះ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយជាទីកន្លែងដែលប្រជាពលរដ្ឋមកស្នើសុំ និងទទួលឯកសារសំណុំបែបបទ និងព័ត៌មានពេញលេញពាក់ព័ន្ធនឹងប្រភេទសេវារដ្ឋបាល កម្រៃ និងពេលវេលានៃការផ្តល់សេវារដ្ឋបាល។ អង្គភាព ឬការិយាល័យច្រកចេញចូលតែមួយ ដែលបានបង្កើតឡើងនៅគ្រប់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌចំនួន៨៣ កំពុងផ្តល់សេវារដ្ឋបាលពាក់ព័ន្ធនឹងវិស័យចំនួន១៤ (នីត្យានុកូលកម្ម អត្រានុកូលដ្ឋាន អប់រំ សុខាភិបាល ដឹកជញ្ជូន សុរិយោដី សំណង់ ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ កសិកម្ម ឧស្សាហកម្ម និងរ៉ែនិងថាមពល)។ ស្របពេលជាមួយគ្នានេះ ការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតឡើងដើម្បីទទួលបណ្តឹង និងផ្តល់ព័ត៌មានភាពមិនប្រក្រតី និងភាពខ្វះខាត ប្រព្រឹត្តដោយបុគ្គលិកនៃរដ្ឋបាលពាក់ព័ន្ធចំពោះអ្នកទទួលសេវាសាធារណៈ។ ក្រៅពីនេះ នៅមានសេវាសាធារណៈមួយចំនួន បាននិងកំពុងរៀបចំផ្ទេរតាមរយៈយន្តការផ្ទេរមុខងារ និងធនធានពីបណ្តាក្រសួង ស្ថាប័ន ទៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឲ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោះបីមានការបែកចែក និងការកំណត់ប្រភេទសេវាសាធារណៈ និងសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក៏ដោយ ក៏ការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់មានភាពច្បាស់លាស់ និងមិនទាន់បានធ្វើសមាហរណកម្ម និងតម្រឹមគ្នាក្នុងគោលដៅដើម្បីអោយការប្រើប្រាស់ធនធានដែលមានកម្រិតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទអាចសម្រេចឱ្យបាននូវសមិទ្ធផលជាអតិបរមា។

## ២.៤ ការគ្រប់គ្រងថវិកា

### ២.៤.១.អំពីថវិកា

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសំដៅដល់ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ទទួលបានការឧបត្ថម្ភធនឬការផ្ទេរធនធានថវិកាពីថវិកាថ្នាក់ជាតិដើម្បីបំពេញចំណាយរបស់ខ្លួន។ ថវិការដ្ឋបាលរាជធានីខេត្តមួយចំណែកធំមានប្រភពពីចំណូលផ្ទាល់នៅមូលដ្ឋាន (ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ) និងមួយចំណែកទៀតទទួលបានការផ្ទេរថវិកាជាឧបត្ថម្ភធនពីថ្នាក់ជាតិ។ ចំណែកថវិការដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ទទួលបានស្ទើរតែទាំងស្រុងដោយការផ្ទេរថវិកាពីថ្នាក់ជាតិតាមរយៈមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។ ការបែងចែកប្រភេទចំណូលសារពើពន្ធ គឺស្ថិតក្នុងទម្រង់នៃការចែករំលែកប្រាក់ចំណូលដុល (១០០%) ដែលកំណត់ដោយច្បាប់ជាមួយនឹងការត្រួតពិនិត្យទាំងស្រុងលើរចនាសម្ព័ន្ធពន្ធ ការកំណត់មូលដ្ឋានគិតពន្ធ និងអត្រាពន្ធជាដើម ដែលថ្នាក់ជាតិនៅតែដើរតួនាទីសំខាន់ក្នុងកិច្ចការនេះ។ យ៉ាងណាមិញ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចលុបចោលការយកកម្រៃលើសេវាសាធារណៈមួយចំនួន រួមទាំងពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះ (ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងជលយានយន្តធុនតូច) និងពន្ធសត្តឃាត។

ចំណូលសារពើពន្ធមានភាពខុសគ្នាខ្លាំងរវាងខេត្តមួយទៅខេត្តមួយ ផ្អែកតាមសក្តានុពលនៃការប្រមូលចំណូលនៅតាមតំបន់នីមួយៗ។ ចំណូលសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រមាណ៣ភាគ៤ ត្រូវបានប្រមូលនៅរាជធានីភ្នំពេញ ដែលក្នុងនោះពន្ធលើអាករបំភ្លឺសាធារណៈត្រូវបានប្រមូលស្ទើរតែទាំងស្រុងនៅរាជធានីភ្នំពេញ។ ការប្រមូលចំណូលមិនមែនសារពើពន្ធពុំទាន់អនុវត្តបានល្អនៅឡើយ បើប្រៀបធៀបទៅនឹងចំណូលសារពើពន្ធ។

ដើម្បីបង្កើនធនធានហិរញ្ញវត្ថុបន្ថែមជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំបង្កើនកញ្ចប់ថវិកាបន្ថែមចំនួន ០,១%ប្រចាំឆ្នាំជូនរដ្ឋបាលក្រុង ស្រុក និង ឃុំ សង្កាត់។ មូលនិធិក្រុង ស្រុក នឹងកើនពី ១,១% (ឆ្នាំ២០១៩) ដល់ ១,៥% (ឆ្នាំ២០២៣) និងមូលនិធិឃុំ សង្កាត់នឹងកើនពី ៣% (ឆ្នាំ២០១៩) ទៅ ៣,៤% (ឆ្នាំ២០២៣) នៃចំណូលចរន្តថវិកាថ្នាក់ជាតិដែលបានអនុម័តឆ្នាំមុន។ លើសពីនេះ ដើម្បីបង្កើននូវប្រភពធនធានហិរញ្ញវត្ថុបន្ថែមទៀត ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៣% និងរដ្ឋបាលឃុំ សង្កាត់ ១% សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចប្រគល់ចំណូលពីពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន តាមប្រកាសលេខ១៤៣១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី *«ការប្រគល់ពន្ធលើឈ្នួលអចលនទ្រព្យ និងចលនទ្រព្យជូនរដ្ឋបាលថ្នាក់ក្រោមជាតិ»*។

ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានវិសាលភាពធំ ដែលមានរដ្ឋបាលច្រើនអនុវត្តថវិកា និងត្រូវមានតម្លាភាព និងគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោម-

ជាតិនីមួយៗ។ បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានអនុម័ត ឯកសារថវិកាពាក់ព័ន្ធ និងសៀវភៅថវិកាសម្រាប់ការគ្រប់គ្រងថវិការាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ព័ត៌មានស្តីពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២.៤.២. រដ្ឋបាលរាជធានី ខេត្ត

បន្ទាប់ពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានកំណត់ រាជរដ្ឋាភិបាលដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាជាតិ។ ផ្អែកលើសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសារាចរណែនាំដោយឡែកមួយទៀត ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្រ្តថវិកា គឺជាផែនការបីឆ្នាំរំកិលតាមអភិក្រមពីក្រោមឡើងលើ ដែលត្រូវបានរៀបចំជារៀងរាល់ឆ្នាំដោយរដ្ឋបាលរាជធានី ខេត្ត។ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំត្រូវរៀបចំរយៈពេល៥ឆ្នាំម្តង ចំណែកកម្មវិធីវិនិយោគ៣ឆ្នាំរំកិលត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ផែនការយុទ្ធសាស្រ្តថវិការដ្ឋបាលរាជធានី ខេត្តត្រូវបានរៀបចំដោយផ្អែកលើកម្មវិធី និងអាទិភាព ដែលបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ រួចដាក់ឱ្យក្រុមប្រឹក្សា រាជធានី ខេត្ត ពិនិត្យនិងអនុម័តមុននឹងបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការយុទ្ធសាស្រ្តថវិកានេះ ត្រូវបានរៀបចំទៅតាមគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព ដោយមានខ្លឹមសារពិពណ៌នាអំពីគោលបំណង សូចនាករគន្លឹះនិងគោលដៅសូចនាករ ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ ការគ្រោងថវិការបស់រដ្ឋបាលរាជធានី ត្រូវរួមបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ និង សង្កាត់ចំណុះរដ្ឋបាលរាជធានី ដែលជាថវិកាបានពីការវិភាជ និង ផ្ទេរពីមូលនិធិឃុំ សង្កាត់ និង ចំណូលដែលរដ្ឋបាលខណ្ឌ និង សង្កាត់ប្រមូលខ្លួនឯង ។ ថវិការដ្ឋបាលរាជធានី ខេត្ត បន្ទាប់ពីក្រុមប្រឹក្សាពិនិត្យនិងអនុម័តហើយ ត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីចរចា និងយល់ព្រម។ ថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ជាផ្នែកមួយនៃថវិកាជាតិ។ ផ្អែកលើមូលដ្ឋានកញ្ចប់គម្រោងចំណូលថវិកាប្រចាំឆ្នាំដែលបានកំណត់រួច អភិបាលនៃគណៈអភិបាលរាជធានីត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់រដ្ឋបាលខណ្ឌ និងសង្កាត់នីមួយៗដើម្បីរៀបចំគម្រោងថវិកាលម្អិតរបស់ខ្លួន។

គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

## ២.៤.៣. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់ចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្រ្តថវិកាទេ ដោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះ គឺផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់

រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួន ដើម្បីពិនិត្យ និងអនុម័ត។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តសាមី ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌមិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទេ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក បន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យនិងអនុម័តថវិការួច មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុបថវិកានេះនៅតាមខេត្តនីមួយៗ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថវិកាក្រុងត្រូវគ្រោងបញ្ចូលថវិកាសង្កាត់ដែលជាថវិកាបានពីការវិភាជ និងផ្ទេរពីមូលនិធិឃុំ សង្កាត់ ព្រមទាំងចំណូលផ្ទាល់នៅមូលដ្ឋាន។ អភិបាលនៃគណៈអភិបាលក្រុងត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់ដល់រដ្ឋបាលសង្កាត់នីមួយៗ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ រដ្ឋបាលក្រុង ស្រុកត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំ រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

## ២.៤.៤. រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ពុំទាន់រៀបចំផែនការយុទ្ធសាស្ត្រថវិកាទេ ដោយការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះ គឺផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល៣ឆ្នាំរំកិលរបស់រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍រដ្ឋបាលឃុំ សង្កាត់ត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួន ដើម្បីពិនិត្យ និងអនុម័ត។ ផែនការអភិវឌ្ឍន៍ឃុំ និងសង្កាត់ចំណុះរាជធានីត្រូវបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តសាមីដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍សង្កាត់ចំណុះក្រុង ត្រូវបញ្ជូនទៅរដ្ឋបាលក្រុងដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍នេះ មិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តទេ។ រដ្ឋបាលឃុំ សង្កាត់នីមួយៗរៀបចំថវិកាដោយខ្លួនឯង រួចដាក់ឱ្យក្រុមប្រឹក្សាខ្លួនពិនិត្យនិងអនុម័ត បន្ទាប់មកបញ្ជូនទៅរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ និងផ្តល់អនុលោមភាព។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងដំណាច់ឆ្នាំទៅអភិបាលនៃគណៈអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជារួម ការគ្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានរៀបចំឈរលើមូលដ្ឋានកំណើនប្រចាំឆ្នាំ ដោយផ្អែកលើចំណូលថវិកាដែលបានពីការផ្ទេរពីថ្នាក់ជាតិ ចំណូលផ្ទាល់របស់រដ្ឋបាលនីមួយៗ តម្រូវការអភិវឌ្ឍន៍ជាអាទិភាព គោលនយោបាយតម្លើងប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល និងកំណើនបុគ្គលិកមន្ត្រីរាជការ។

### ២.៤.៥. ការត្រួតពិនិត្យការអនុវត្តថវិកា

ក្នុងការអនុវត្តបច្ចុប្បន្ន យន្តការគ្រប់គ្រង និងនីតិវិធីអនុវត្តនៃការបញ្ជាចំណាយសម្រាប់រដ្ឋបាលរាជធានីខេត្ត ដូចគ្នាទៅនឹងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ដែលមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការត្រួតពិនិត្យផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ ហើយរតនាគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈត្រួតពិនិត្យ និងទូទាត់ចំណាយថវិកា។ រដ្ឋបាលក្រុង ស្រុក មិនតម្រូវឱ្យមានការស្នើសុំធានាចំណាយ ប៉ុន្តែតម្រូវឱ្យមានការត្រួតពិនិត្យថវិកាពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនធ្វើការទូទាត់។ ចំណែកថវិការដ្ឋបាលឃុំ សង្កាត់ត្រូវបានផ្តល់សិទ្ធិស្វ័យសម្រេចក្នុងការចាត់ចែងបញ្ជាចំណាយដោយខ្លួនឯង។ ការត្រួតពិនិត្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ទាំងក្នុងដំណាក់កាលធានាចំណាយ កិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់ លើកលែងតែថវិការដ្ឋបាលឃុំ សង្កាត់។ ការត្រួតពិនិត្យថវិកាត្រូវបានអនុវត្តដូចនៅថ្នាក់ជាតិដែរ ដោយផ្អែកលើអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យករសាធារណៈ។

### ២.៥. កិច្ចលទ្ធកម្ម

បច្ចុប្បន្ន ការគ្រប់គ្រង និងការអនុវត្តលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺផ្អែកលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ២០១២ តែមួយដូចនៅរដ្ឋបាលថ្នាក់ជាតិ។ ក្រៅពីច្បាប់នេះ មានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនទៀតត្រូវបានបង្កើតឡើងសម្រាប់គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវគ្រប់គ្រង និងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដោយឡែកដែលចេញដោយក្រសួងមហាផ្ទៃ។ ការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវបានធ្វើឡើងដោយគណៈកម្មាធិការលទ្ធកម្ម ឬ/និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ គឺជាប្រធានគណៈកម្មាធិការលទ្ធកម្ម។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចចេញគោលការណ៍ និងប្រកាសណែនាំ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ។ រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំដោយផ្អែកលើផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្នុងលេខកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យនិងសម្រេចដោយគណៈកម្មាធិការលទ្ធកម្មរបស់ខ្លួន មុននឹងបញ្ជូនទៅក្រុមប្រឹក្សារៀងៗខ្លួនពិនិត្យ និងផ្តល់ការឯកភាព។ បន្ទាប់មក ផែនការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណែកផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការអនុម័តជាផ្លូវការឱ្យបានមុនឆ្នាំអនុវត្តថវិកា។ ដោយឡែករដ្ឋបាលឃុំ សង្កាត់ មិនតម្រូវឱ្យមានផែនការលទ្ធកម្មប្រចាំឆ្នាំឡើយ។ ចំពោះមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបញ្ជូន

ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ដើម្បីពិនិត្យ និងដាក់ចូលជាឧបសម្ព័ន្ធជាមួយនឹងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួងស្ថាប័នសាមី រួចបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ការអនុម័តជាផ្លូវការឱ្យបានមុនឆ្នាំអនុវត្តថវិកា។

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែក មន្ទីរជំនាញរាជធានី ខេត្តត្រូវផ្ញើរបាយការណ៍មកក្រសួងស្ថាប័នសាមី ដើម្បីបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បច្ចុប្បន្ន ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ បាននិងកំពុងអនុវត្តតាមបែបវិមជ្ឈការ និងវិសហមជ្ឈការលទ្ធកម្មសាធារណៈ ដោយផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ជាពិសេស រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈប្រកាសអន្តរក្រសួងលេខ៥៦៨ សហវ.ប្រក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រគល់សិទ្ធិសម្រេចលើកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានពីរកម្រិត គឺកិច្ចលទ្ធកម្មស្ថិតក្រោមកម្រិតទឹកប្រាក់សិទ្ធិសម្រេចដោយរដ្ឋបាលថ្នាក់ក្រោមជាតិផ្ទាល់ និងកិច្ចលទ្ធកម្មលើសកម្រិតទឹកប្រាក់សិទ្ធិសម្រេចដែលត្រូវស្នើសុំការពិនិត្យសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថវិការដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ២.៦. ច្បាប់, បទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ការគ្រប់គ្រងថវិកា

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានគ្រប់គ្រង និងអនុវត្តតាមគោលការណ៍ និង វិធាននានា ដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ បានចែងអំពីគោលការណ៍ និងវិធានសំខាន់ៗសម្រាប់គ្រប់គ្រងនិងអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ក្រៅពីច្បាប់ទាំងពីរនេះ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនទៀតត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់ការរៀបចំ និងអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ លិខិតបទដ្ឋានគតិយុត្តទាំងនោះ ទោះបីជាត្រូវបានរៀបចំឡើងក្នុងគោលដៅ និងគោលបំណងរួមដើម្បីឆ្លើយតបបានទៅនឹងគោលការណ៍ និង វិធានដែលបានកំណត់ដោយច្បាប់ទាំងពីរនេះក៏ដោយ ក៏លិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានរៀបចំឡើងដាច់ដោយឡែកៗពីគ្នាសម្រាប់គ្រប់គ្រង និងអនុវត្តថវិការបស់ថ្នាក់នីមួយៗនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

# ៣. ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ឆ្លងតាមបទពិសោធន៍នៃការអនុវត្តកន្លងទៅ និងផ្អែកតាមលទ្ធផលនៃការសិក្សាពិនិត្យឡើងវិញ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បានឈានទៅរកសេចក្តីសន្និដ្ឋានជារួមថា ទិសដៅយុទ្ធសាស្ត្រនៃប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវកែសម្រួលស្របពេលជាមួយនឹងយុទ្ធ-សាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ។ រាជរដ្ឋាភិបាលបានដាក់ចេញឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ដោយបានកំណត់នូវមូលដ្ឋានគ្រឹះ និងទិសដៅសំខាន់ៗរួចជាស្រេច សម្រាប់ការរៀបចំឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជា-យ៉ាងនេះក្តី ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសក្របខ័ណ្ឌពេលវេលា ដោយត្រូវពិនិត្យឡើងវិញនូវបទពិសោធន៍នៃការអនុវត្តកន្លងមក និងបរិការណ៍បច្ចុប្បន្ននៃកម្ពុជារួមទាំងកត្តាសមត្ថភាព និងធនធាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈកាន់តែសាមញ្ញ ទន់ភ្លន់ និងប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ក្នុងគោលដៅផ្តល់ឆន្ទានុសិទ្ធិកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនៅក្នុងការអនុវត្តថវិកា។

ផ្នែកទី៣នេះ នឹងពិនិត្យឡើងវិញនូវបណ្តាគោលបំណងពាក់ព័ន្ធនៃឯកសារទស្សនាទាន បទពិសោធន៍មេរៀនដែលទទួលបានពីការអនុវត្តជាក់ស្តែង និងទិសដៅសំខាន់ៗសម្រាប់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់-ក្រោមជាតិដែលបានគូសរំលេចក្នុងឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដើម្បីកំណត់ក្របខ័ណ្ឌពេលវេលា និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.១. ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០

ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ បានកំណត់គោលបំណងនៃការផ្លាស់ប្តូរជាបណ្តើរៗ ជាជំហានៗ ពី *«ប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ »* ទៅរក *«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការ»* ត្រឹមឆ្នាំ២០២០។ ឯកសារទស្សនាទានបានកំណត់គោលបំណងនិងវិសាលភាពនៃការកែទម្រង់ក្នុងក្របខ័ណ្ឌនៃវដ្តថវិកា ជាពិសេស ត្រូវធានាឱ្យបាននូវប្រព័ន្ធថវិកាមួយមានឯកភាព សង្គតិភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកា។ ក្នុងទិសដៅនេះ ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវតម្រឹមជាមួយនឹងប្រព័ន្ធថវិកាថ្នាក់ជាតិ ដូចខាងក្រោម ÷

- ធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ពិសេស គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

- កែលម្អ និងផ្លាស់ប្តូរជាជំហានៗនៃវដ្តថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិ ពិសេស កំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលទាំង៤នៃវដ្តថវិកា។
- ប្រព័ន្ធ និងការគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងថ្នាក់ជាតិ ដោយប្រើប្រាស់ចំណាត់ថ្នាក់ថវិកា ប្លង់គណនី និងទម្រង់របាយការណ៍ដូចគ្នា។

សរុបមក ឯកសារទស្សនាទាននេះ មានសារៈប្រយោជន៍សម្រាប់ជាមគ្គុទ្ទេសក៍នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមអភិក្រមកែទម្រង់ជាបណ្តើរៗ និងជាជំហានៗ ដោយត្រូវតម្រឹមជាមួយនឹងប្រព័ន្ធថវិកាថ្នាក់ជាតិ ដែលមកដល់ពេលនេះ គឺកំពុងស្ថិតនៅក្នុងទិសដៅត្រឹមត្រូវ។

## ៣.២. ការត្រួតពិនិត្យលើការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ការសិក្សាវាយតម្លៃអំពីភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) បានបង្ហាញថា ការផ្តួចផ្តើមដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធីនៅរដ្ឋបាលរាជធានី ខេត្ត គឺជាវឌ្ឍនភាពមួយសំខាន់ ហើយការកំណត់ចំនួនគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា គឺជាចំណុចវិជ្ជមានក្នុងការជំរុញឱ្យផ្តោតការយកចិត្តទុកដាក់លើសមិទ្ធកម្មឱ្យបានកាន់តែខ្លាំងឡើង ជាពិសេស បានធ្វើឱ្យដំណើរការរៀបចំ និង អនុវត្តថវិកាកម្មវិធីកាន់តែមានប្រសិទ្ធភាព និងគ្រប់គ្រងបាន។ គ្រប់រដ្ឋបាលរាជធានី ខេត្តទាំងអស់តម្រូវឱ្យរៀបចំថវិកាប្រចាំឆ្នាំទៅតាមគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពសម្រាប់ការពិភាក្សារៀបចំកញ្ចប់ថវិកាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអនុវត្តផ្ទាល់ដោយអង្គភាពថវិកានៃរដ្ឋបាលរាជធានី ខេត្ត។ ទោះជាយ៉ាងនេះក្តី ការរៀបចំថវិកាផ្អែកលើធាតុចូលនៅតែជាឯកសារផ្លូវការសម្រាប់ដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យនិងសម្រេច។

*«អង្គភាពថវិកា»*ត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពជាម្ចាស់ក្នុងការគ្រប់គ្រង និងអនុវត្ត ដោយផ្សារភ្ជាប់រវាងធនធានទៅនឹងការទទួលខុសត្រូវចំពោះការអនុវត្ត និងសមិទ្ធកម្ម។ អង្គភាពថវិការបស់រដ្ឋបាលរាជធានី ខេត្ត គឺជារដ្ឋបាលរាជធានី ខេត្ត ដែលទទួលបន្ទុកផ្ទាល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្នុងនាមជាអាណាប័កដើមខ្សែ។ *អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ* គឺទីចាត់ការហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត ដែលមានតួនាទីចម្បងមួយចំនួន គឺការរៀបចំថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យនិងតាមដានការអនុវត្តថវិកា។ ទន្ទឹមនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ការបណ្តុះបណ្តាល ការគាំទ្រផ្នែកបច្ចេកទេស និងមគ្គុទ្ទេសក៍ជាច្រើនដល់រដ្ឋបាលរាជធានី ខេត្តមក ការរៀបចំថវិកា និងផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកាកម្មវិធីបានទទួលការគាំទ្រ និងចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរដ្ឋបាលរាជធានី ខេត្ត។

ជាមួយនឹងវឌ្ឍនភាពខាងលើ ការសិក្សាដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ក្របខ័ណ្ឌគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ (PEFA) បានបង្ហាញនូវចំណុចខ្វះខាតមួយចំនួន ដែលទាមទារនូវដំណោះស្រាយ រួមមាន÷

- ការរៀបចំខ្លឹមសារនៃផែនការយុទ្ធសាស្ត្រថវិកាក៏នៅមានភាពទន់ខ្សោយ ដោយសារការយល់ដឹងផ្នែកទស្សនាទាននៅមានកម្រិត ហើយសមត្ថភាពខុសៗគ្នានៃរដ្ឋបាលរាជធានី ខេត្ត បានធ្វើឱ្យការរៀបចំរចនាសម្ព័ន្ធកម្មវិធីនៅមិនទាន់បានល្អ
- ការចូលរួមពីគ្រប់ទីចាត់ការក្នុងរដ្ឋបាលរាជធានី ខេត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីមិនទាន់បានពេញលេញ
- ការកំណត់សូចនាករសមិទ្ធកម្ម និងលទ្ធផលចុងក្រោយមិនទាន់បានល្អដោយសារបញ្ហាសមត្ថភាព
- កង្វះទិន្នន័យជាទៀងទាត់ និងអាចជឿជាក់បានជាមូលហេតុចម្បងដែលធ្វើឱ្យរបាយការណ៍អំពីសូចនាករសមិទ្ធកម្មសំខាន់ៗមិនអាចយកទៅប្រើប្រាស់បាន ក្នុងគោលដៅរៀបចំផែនការថវិកាឱ្យមានប្រសិទ្ធភាព។

ជារួម ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មពេញលេញសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺមិនអាចសម្រេចបានទេតាមទិសដៅនៃទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា២០១៣-២០២០ ដោយសារបញ្ហាប្រឈមមួយចំនួនដូចបានរៀបរាប់ខាងលើ ពិសេស សមត្ថភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិនៅមានកម្រិត។

## ៣.៣. ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

ឆ្លងកាត់តាមបទពិសោធន៍នៃការអនុវត្តតាមទិសដៅនៃទស្សនាទានស្តីពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០ កន្លងមក និងផ្អែកតាមការសិក្សាវាយតម្លៃរបស់គណៈកម្មាធិការដឹកនាំការងារកែ-ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអ្នកជំនាញពាក់ព័ន្ធស្តីពីវឌ្ឍនភាពនៃការអនុវត្តថវិកាកម្មវិធី បានបង្ហាញថា ការកំណត់គោលដៅឆ្នាំ២០២០ ក្នុងការចាប់ផ្តើមអនុវត្ត *«ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម»* គឺមានមហិច្ឆតាខ្ពស់ពេក។ ក្នុងន័យនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចាត់តាំងក្រុមការងារមួយ ឱ្យរៀបចំឯកសារយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ជាមូល-ដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកាក្នុងរយៈពេលវែងគឺ *«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥»* ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងតថភាពជាក់ស្តែងនៃកម្ពុជា។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានឆ្លងកាត់ការសិក្សា និងដកស្រង់បទពិសោធន៍ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ និងពីបណ្តាប្រទេសមួយចំនួន ដូចជា ប្រទេសបារាំង ស៊ុយអែត ថៃ និងម៉ាឡេស៊ី ជាពិសេស ផ្អែកលើបទពិសោធន៍នៃការអនុវត្តការងារជាក់ស្តែងរយៈពេលជាច្រើនឆ្នាំរបស់កម្ពុជាផ្ទាល់ ក៏ដូចជា

ការចូលរួមចែករំលែកបទពិសោធន៍ពីអ្នកជំនាញការជាច្រើននាក់ ព្រមទាំងបានឆ្លងកាត់ការពិភាក្សាជាច្រើនលើកច្រើនសារនៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សំខាន់ៗ។

*ជាលទ្ធផល យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានផ្តល់ជាក្របខ័ណ្ឌទស្សនាទានសម្រាប់តម្រង់ទិសការរៀបចំ* ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ -២០២៥»*** *ដូចខាងក្រោម÷*

ទី១-ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផ្អែកលើ ***«ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច»*** ***«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម»*** និង ***«ក្របខ័ណ្ឌថវិការយៈពេលមធ្យម»*** តែមួយ។

ទី២-ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំមានតែមួយ ដែលរួមមានថវិកាថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ថវិការដ្ឋបាលរាជធានី ខេត្ត នឹងឆ្លុះបញ្ចាំងជាសរុបតាមថ្នាក់រដ្ឋបាលនីមួយៗ ដោយចែកជាថវិកាចរន្ត និងថវិកាមូលធនជាឧបសម្ព័ន្ធនៃច្បាប់។ ដោយឡែក ថវិការបស់រដ្ឋបាល ក្រុង ស្រុក និងឃុំ សង្កាត់ នឹងត្រូវឆ្លុះបញ្ចាំងជាទំហំសរុបដុល។

ទី៣- រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក តាមរយៈការធ្វើការតម្រឹមផែនការនីយកម្ម ដើម្បីសម្រេចគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ **(ដូចដែលបានបង្ហាញក្នុងដ្យាក្រាមទី១ខាងក្រោម)**។

ទី៤-គំរូនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិរបស់ប្រទេសបារាំងបានផ្តល់ជាមូលដ្ឋានទស្សនាទានដ៏សំខាន់សម្រាប់យកមកគិតគូររៀបចំប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបរិបទរបស់កម្ពុជា ពិសេស ***«ការអនុវត្តនិងការត្រួតពិនិត្យថវិកា»***។

ទី៥-ការផ្តល់អំណាច និងការទទួលខុសត្រូវដល់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត។

ទី៦-ការផ្តល់សិទ្ធិសម្រេច និងការទទួលខុសត្រូវដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តថវិកា ប៉ុន្តែជាកម្មវត្ថុនៃការត្រួតពិនិត្យក្រោយចំណាយដោយរតនាគាររាជធានី ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ។

ទី៧-ការធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍នៅថ្នាក់ក្រោមជាតិ និងបង្កើនសមត្ថភាពថ្នាក់ក្រោមជាតិក្នុងការធ្វើរបាយការណ៍។

ជារួម ទោះបីជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានផ្តល់នូវក្របខ័ណ្ឌទស្សនាទានសម្រាប់តម្រង់ទិសក្នុងការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងការអនុវត្តថវិកាព័តិមានសមិទ្ធកម្មនៅឆ្នាំ២០២៥ក្តី ក៏ ***«ក្របខ័ណ្ឌពេលវេលា»*** នេះចាំបាច់ត្រូវពិនិត្យឡើងវិញឱ្យសមស្របនៅក្នុងបរិការណ៍ និងសមត្ថភាពជាក់ស្តែងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា។

*ដ្យាក្រាមទី១÷ក្របខ័ណ្ឌទស្សនាទាននៃសមាហរណកម្មផែនការនីយកម្មថវិកាថ្នាក់ជាតិ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ*




*ប្រភពឯកសារ÷យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥*

### ៣.៤. ទិសដៅ និងក្របខ័ណ្ឌពេលវេលានៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ឯកសារយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់យកគោលដៅសម្រាប់ធ្វើការផ្លាស់ប្តូរប្រព័ន្ធថវិកាជាតិជាជំហានៗ ដើម្បីឆ្ពោះទៅអនុវត្ត ***«ថវិកាព័ត៌មានសមិទ្ធកម្ម»*** នៅឆ្នាំ២០២៥ ។ ប៉ុន្តែផ្អែកតាមបទពិសោធន៍ និងការអនុវត្តជាក់ស្តែង ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពស្មុគស្មាញ និងសមត្ថភាពមន្ត្រីជំនាញនៅមានកម្រិត ដែលធ្វើឱ្យក្របខ័ណ្ឌពេលវេលានៃការកែទម្រង់ពីប្រព័ន្ធ ***«ថវិកាកម្មវិធី»*** ទៅប្រព័ន្ធ ***«ថវិកាព័ត៌មានសមិទ្ធកម្ម»*** ដែលបានកំណត់ខាងលើ មិនសមស្របនៅក្នុងបរិការណ៍នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជានោះទេ។

ក្នុងន័យនេះ ***«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥»*** មានទិសដៅពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាបណ្តើរៗ ដើម្បីឈានដល់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ដោយធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណងគោល-នយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើសមាហរណកម្មផែនការនីយកម្មកម្រិតផែនការយុទ្ធសាស្ត្រ គឺការលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ។ ការធ្វើសមាហរណកម្មនៃផែនការនីយកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើឱ្យការគ្រោងផែនការ

សកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងបីប្រភេទមានលក្ខណៈប្រមូលផ្តុំ ដើម្បីតម្រង់ទិស បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ជាងមុន សម្រាប់ជាមូលដ្ឋានក្នុងការតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត។ ការធ្វើការកែលម្អ និងផ្លាស់ប្តូរជាជំហានៗវដ្តថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិ ពិសេស កំណត់ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកា។ ការធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងការបង្កើនសមត្ថភាពថ្នាក់ក្រោមជាតិឱ្យធ្វើរបាយ-ការណ៍លទ្ធផលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត។

ជារួម ការអនុវត្ត **«ថវិកាព័ត៌មានសមិទ្ធកម្ម»** នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើឡើងនៅក្រោយឆ្នាំ ២០២៥។ ចក្ខុវិស័យសម្រាប់ឆ្នាំ២០២៥ គឺការប្រែក្លាយជាបណ្តើរៗនូវប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិកម្ពុជា តាមរយៈការកំណត់ក្របខ័ណ្ឌពេលវេលាច្បាស់លាស់ និងការដាក់ចេញផែនការសកម្មភាពកែទម្រង់តាមអភិក្រម ដែលមានលក្ខណៈសាមញ្ញ ទន់ភ្លន់ និងតម្លាភាព ដោយត្រូវបានផ្តល់ឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ស្របតាមសមត្ថភាព និងតថភាពជាក់ស្តែងនៃកម្ពុជា។

៙៙✻៙៙

# ៤. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥

គោលដៅនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ គឺពង្រឹងការអនុវត្តថវិកាកម្មវិធីឱ្យបានពេញលេញ និងកសាងមូលដ្ឋានសម្រាប់ការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ដើម្បីធានាឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ។ ក្នុងគោលដៅនេះ ការធ្វើសមាហរណកម្មផែនការនីយកម្មមានភាពចាំបាច់ដើម្បីឱ្យផែនការយុទ្ធសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក និងតម្រឹមទៅនឹងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ។ ការរៀបចំផែនការថវិកាប្រចាំឆ្នាំចាំបាច់ត្រូវធានាឱ្យមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា និងត្រូវឱ្យមានការចូលរួមកាន់តែទូលំទូលាយពីភាគីពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ការវិភាជ និងការអនុវត្តថវិកានឹងត្រូវបានបង្កើនប្រសិទ្ធភាពថែមទៀត តាមរយៈការកែលម្អ និងការធ្វើសាមញ្ញកម្មនីតិវិធីចំណាយ ជាពិសេស ការផ្តល់ឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ការរៀបចំរបាយការណ៍នឹងត្រូវធ្វើឱ្យបានទាន់ពេលវេលា ហើយការបង្កើនសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើរបាយការណ៍តាមកម្មវិធីនឹងត្រូវពង្រឹងបន្ថែមទៀត។

ផ្នែកទី៤នេះ ដាក់ចេញនូវសកម្មភាពកែទម្រង់តាមអភិក្រមដែលមានលក្ខណៈសាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព ដោយផ្តោតលើសមាសធាតុគន្លឹះនៃវដ្តថវិកា និងសមាសធាតុដែលជារចនាសម្ព័ន្ធទ្រទ្រង់រួមមានក្របខ័ណ្ឌគតិយុត្ត ការកសាងនិងអភិវឌ្ឍសមត្ថភាព និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥ ។ ក្រៅពីនេះ នៅមានការកែទម្រង់មួយទៀត ដែលចាត់ទុកជាសមាសធាតុសំខាន់នៃការកែទម្រង់ប្រព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤.១. វដ្តថវិកា

### ៤.១.១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

#### ក. ការអនុវត្តបច្ចុប្បន្ន

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់បានធ្វើសមាហរណកម្មនៃផែនការយុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើការតម្រឹមជាមួយផែនការយុទ្ធសាស្ត្ររបស់មន្ទីរជំនាញរាជធានី ខេត្តនៅឡើយទេ ដែលជាហេតុនាំឱ្យការប្រើប្រាស់ធនធានដែលមានកម្រិតមិនទាន់ទទួលបានសមិទ្ធផលជាអតិបរមា។ ម្យ៉ាងទៀត ការតម្រឹមផែនការ/កម្មវិធីរវាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាមន្ទីរជំនាញរាជធានី ខេត្តនៅមិនអាចសម្រេចទៅបាន ដោយសារតែពុំទាន់មានការប្រឹក្សាយោបល់គ្នា និងសហការគ្នាឱ្យបាន

គ្រប់គ្រាន់រវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺអនុវត្តក្នុងកម្រិតរដ្ឋបាលរាជធានី ខេត្ត ដែលផែនការនេះមិនរួមបញ្ចូលផែនការអភិវឌ្ឍន៍ក្រុង ស្រុក និងឃុំ សង្កាត់។

ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមូលដ្ឋានសំខាន់សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំដាច់ដោយឡែករវាងថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាមានយន្តការសម្របសម្រួលពិគ្រោះយោបល់តាមរយៈ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដើម្បីធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដោយ ក៏ភាពខុសគ្នានៃពេលវេលា វិធីសាស្ត្រ និងអភិក្រម បានធ្វើឱ្យដំណើរការនៃការធ្វើសមាហរណកម្មបញ្ចូលគ្នានេះពិបាកនឹងសម្រេចបាន។

ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្ត ត្រូវបានរៀបចំតាមអភិក្រមពីក្រោមឡើងលើដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិ។ ជាមួយគ្នានេះ សមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្តនៅមានកម្រិត ដែលបង្ហាញឱ្យឃើញពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ជាពិសេស ការគ្រោងថវិកា ការកំណត់សូចនាករសមិទ្ធកម្មនៅក្នុងកម្មវិធី និងចង្កោមសកម្មភាព។ ប្រការនេះបានធ្វើឱ្យការរៀបចំផែនការថវិកាមិនទាន់ផ្សារភ្ជាប់បានទាំងស្រុងទៅនឹងគោលបំណងគោលនយោបាយ ដែលធ្វើឱ្យការប្រើប្រាស់ធនធានសាធារណៈមិនទាន់មានប្រសិទ្ធភាព។

### ខ. ទិសដៅឆ្នាំ២០២៥

ផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្ត នឹងត្រូវធ្វើការកែលម្អជាបណ្តើរៗឱ្យក្លាយជាផែនការយុទ្ធ-សាស្ត្រថវិការួម ហៅថា **«ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត»** តាមរយៈការធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួងស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត) ដូចបានបង្ហាញក្នុងដ្យាក្រាមទី១ក្នុងផ្នែកទី៣ខាងលើ។ ដំណើរការនេះ គឺធានាឱ្យមានការផ្សារ-ភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពរវាងផែនការ/កម្មវិធីនៃថវិកាថ្នាក់ក្រោមជាតិទៅនឹងអាទិភាពជាតិ/ផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតក្នុងការសម្រេចឱ្យបានសមិទ្ធផលជាអតិបរមា។ តាមគោលដៅនេះ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវរៀបចំផែនការអន្តរាគមន៍របស់ខ្លួនដោយផ្តោតជាសំខាន់លើវិស័យអាទិភាពនៅមូលដ្ឋាន ដើម្បីគាំទ្រដល់អាទិភាពគោលនយោបាយរដ្ឋបាលរាជធានី ខេត្ត ដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យ និង អាទិភាពជាតិ។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់នឹងត្រូវដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ទៅតាមអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់តាមអភិក្រមពីក្រោមឡើងលើ។ ជាមួយគ្នានេះ ផែនការរបស់មន្ទីរជំនាញរាជធានី ខេត្តនឹងត្រូវយកមកគិតគូរក្នុងដំណើរការកសាងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដើម្បីផ្តល់ភាពងាយស្រួលដល់រដ្ឋបាលរាជធានី ខេត្តក្នុងការតម្រឹមសកម្មភាពរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាព និងចំគោលដៅ។

ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត គឺជាឧបករណ៍សំខាន់ ដែលត្រូវរៀបចំឱ្យមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈការពង្រីកវិសាលភាពឱ្យគ្របដណ្តប់គ្រប់ប្រភពចំណូលទាំងអស់ (ថវិការដ្ឋ ឧបត្ថម្ភធន ការផ្ទេរធនធាន ថវិកាដៃគូ និងចំណូលផ្ទាល់) និងគ្រប់មុខសញ្ញាចំណាយទាំងអស់ (ចំណាយបៀវត្ស ចំណាយចរន្តមិនមែនបៀវត្ស និងចំណាយមូលធន)។ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្តនឹងត្រូវរៀបចំទៅតាមគោលបំណងគោល-នយោបាយ និងកម្មវិធី ដោយមានសេចក្តីពន្យល់ ខ្លឹមសារពិពណ៌នាអំពីគោលបំណង ប្រភេទហិរញ្ញប្បទាន សូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល ក្របខ័ណ្ឌពេលវេលា និងតម្រូវការថវិកា។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវចំពោះកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដែលនឹងត្រូវលើកឡើងនៅក្នុងគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ក្របខ័ណ្ឌថវិការយៈពេលមធ្យមនឹងត្រូវរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលនឹងក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

ដើម្បីសម្រេចបាននូវដំណើរការនៃការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត តម្រូវឱ្យមានការកែលម្អដំណើរការប្រឹក្សាយោបល់ និងការសម្របសម្រួលរវាងក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណាក់កាលនៃការធ្វើផែនការយុទ្ធសាស្ត្រថវិកា។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវធ្វើការសម្របសម្រួលដោយ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មុននឹងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្តត្រួតពិនិត្យនិងអនុម័ត រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ប្រការនេះនឹងជួយកាត់បន្ថយពេលវេលា និងជួយសម្រួលដល់ដំណើរការនៃការរៀបចំ និងត្រួតពិនិត្យផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពជាងមុន។

ជាមួយគ្នានេះ ការបង្កើនការគាំទ្រពីមន្ត្រីជំនាញនៅថ្នាក់ជាតិ តាមរយៈការផ្តល់នូវការប្រឹក្សាយោបល់បច្ចេកទេសទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការចាំបាច់បំផុត។ ចំណុចនេះនឹងលើកយកមកពិភាក្សានៅផ្នែកហេដ្ឋារចនាសម្ព័ន្ធគាំទ្រខាងក្រោម។

ជារួម ដោយសារផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្តត្រូវបានរៀបចំ ដោយផ្អែកលើអាទិភាពតាមវិស័យពីថ្នាក់ជាតិចុះមក, ផែនការយុទ្ធសាស្ត្រថវិកានេះ ក៏ត្រូវផ្តល់ភាពទន់ភ្លន់ឱ្យមានការដាក់បញ្ចូលនូវអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពរនានាពីរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជាអភិក្រមពីក្រោមទៅលើ។

## គ. ផែនទីចង្អុលផ្លូវ

រៀបចំកែលម្អឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធី ដើម្បីធានាឱ្យមានការផ្សារភ្ជាប់ផែនការរបស់រដ្ឋបាលថ្នាក់-ក្រោមជាតិទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយត្រូវកំណត់គោលដៅកម្មវិធី អនុកម្មវិធី និងសូចនាករគន្លឹះសម្រាប់តាមដានការអនុវត្ត និងត្រួតពិនិត្យលទ្ធផល ដោយត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ២០១៩ និងសម្រេចឱ្យ

បាននៅឆ្នាំ២០២០។ ធ្វើសមាហរណកម្មជាបណ្ដើរៗនូវផែនការរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ និងតម្រឹមផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត ដោយត្រូវចាប់ពីឆ្នាំ២០២១តទៅ។

ដើម្បីគាំទ្រដល់ការសម្រេចបានតាមទិសដៅខាងលើ មានសកម្មភាពមួយចំនួន ដូចជា÷

ទី(១)-ពង្រឹងយន្តការសម្របសម្រួល និងពិគ្រោះយោបល់តាមរយៈ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* របស់រាជធានី ខេត្ត ដើម្បីឆ្លើយតបទៅនឹងទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិ ដែលកិច្ចការនេះនឹងត្រូវកំណត់នៅពេលរៀបចំគោលការណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។

ទី(២)-ជ្រើសរើសមន្ត្រីបច្ចេកទេសពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមជាមួយនឹងការផ្ដល់ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និងលក្ខខណ្ឌការងារច្បាស់លាស់។ កិច្ចការនេះនឹងចាប់ផ្ដើមអនុវត្តនៅឆ្នាំ២០២០។

ទី(៣)-ផ្ដល់ការបង្ហាត់បង្រៀន (Coaching and Mentoring) ដល់មន្ត្រីទទួលបន្ទុកការងាររៀបចំផែនការយុទ្ធសាស្ត្រ និងផែនការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤.១.២ ដំណើរការរៀបចំថវិកាប្រចាំឆ្នាំ

### ក. ការអនុវត្តបច្ចុប្បន្ន

ការរៀបចំផែនការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិមានដំណើរការផ្សេងៗគ្នារវាងថវិកាមន្ទីរជំនាញរាជ-ធានី ខេត្ត និងរវាងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ថវិកាមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបានគ្រោងបញ្ចូលក្នុងផែនការថវិកាដែលរៀបចំឡើងដោយក្រសួងស្ថាប័នសាមី ដោយផ្អែកលើផែនការ-នីយកម្មពីលើចុះក្រោមទៅតាមអាទិភាពជាតិ។ គម្រោងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវបានរៀបចំ និងទទួលខុសត្រូវដោយរដ្ឋបាលផ្សេងៗគ្នា ដោយផ្អែកតាមប្រភពថវិកាដែលរៀបចំផ្ទេរពីថវិកាជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការព្យាករនូវលទ្ធភាពចំណូលសរុបរបស់រដ្ឋបាលនីមួយៗ។ គម្រោងថវិការបស់រដ្ឋបាលរាជធានី ត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានី។ គម្រោងថវិការបស់រដ្ឋបាលក្រុងត្រូវបូកបញ្ចូលគម្រោងថវិការដ្ឋបាលសង្កាត់ចំណុះរដ្ឋបាល ក្រុង។

ការរៀបចំផែនការថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ទីរជំនាញរាជធានី ខេត្តផ្អែកតាមយន្តការនៃការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រអាទិភាពផ្សេងៗគ្នា ហើយការរៀបចំផែនការថវិកានេះ ក៏មិនទាន់មានសង្គតិភាពគ្នាទាំងស្រុងជាមួយនឹងយុទ្ធសាស្ត្រអាទិភាពនៅឡើយទេ។ ការរៀបចំផែនការថវិការបស់មន្ទីរជំនាញរាជធានី ខេត្តផ្អែកតាមផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងស្ថាប័ន ដែលបានផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍ជាតិ។ ផែនការថវិការបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវរៀបចំដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលបានផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ខ្លួន។ ចំណែកផែនការថវិការបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ គឺផ្អែកតាមផែនការអភិវឌ្ឍន៍

៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលនីមួយៗ។ ជាទូទៅ ការរៀបចំផែនការថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មានភាពយឺតយ៉ាវ។

ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៅមានកម្រិត។ ការរៀបចំផែនការថវិកានៅរដ្ឋបាលរាជធានី ខេត្ត មាននាយកទីចាត់ការហិរញ្ញវត្ថុជាអ្នកសម្របសម្រួល រៀបចំ ដើម្បីសុំការសម្រេចពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។ នៅរដ្ឋបាលក្រុង ស្រុក មានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុជាអ្នករៀបចំនិងសម្របសម្រួល ដើម្បីសុំការសម្រេចពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក។ នៅរដ្ឋបាល ឃុំ សង្កាត់ មានស្មៀនជាអ្នកសម្របសម្រួលនិងរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីសុំការសម្រេចពីមេឃុំ និងចៅសង្កាត់។ អង្គភាពថវិកាត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពជាម្ចាស់លើការរៀបចំ និងការអនុវត្តថវិកាក្នុងនាមជាអាណាប័កដើមខ្សែ ក៏ប៉ុន្តែមានរដ្ឋបាលខេត្តមួយចំនួនធំនៅមិនទាន់បង្កើតក្រុមការងារថវិកានៅឡើយ។

ការរៀបចំគម្រោងថវិកាកម្មវិធីរបស់រដ្ឋបាលខេត្ត នៅមានភាពយឺតយ៉ាវ និងមិនទាន់មានគុណភាពល្អគ្រប់គ្រាន់។ ការរៀបចំខ្លឹមសារនៃរចនាសម្ព័ន្ធកម្មវិធីមានភាពទន់ខ្សោយ និងមិនទាន់បានល្អគ្រប់ជ្រុងជ្រោយដោយសារការយល់ដឹងផ្នែកទស្សនាទាននៅមានកម្រិត ហើយសមត្ថភាពខុសៗគ្នានៃរដ្ឋបាលរាជធានី ខេត្ត។ ការកំណត់សូចនាករលទ្ធផលនៃកម្មវិធីមិនទាន់ត្រឹមត្រូវល្អ ដោយសារកង្វះទិន្នន័យដែលអាចជឿជាក់បាន សមត្ថភាពយល់ដឹងនៅមានកម្រិត និងការចូលរួមពីគ្រប់ទីចាត់ការក្នុងរដ្ឋបាលរាជធានី ខេត្ត មិនទាន់បានពេញលេញ។

ការរៀបចំថវិកា និងការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង៧ (សេដ្ឋកិច្ច រដ្ឋបាល មុខងារ ភូមិសាស្ត្រ កម្មវិធី មូលនិធិ និងគម្រោង) មិនអាចអនុវត្តបានពេញលេញ។ ចំណាត់ថ្នាក់កម្មវិធី កំពុងដាក់ឱ្យអនុវត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត ដែលអនុវត្តថវិកាកម្មវិធី លើកលែងតែរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ សម្រាប់ចំណាត់ថ្នាក់ពីរទៀត គឺចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់គម្រោង នៅមានការលំបាកក្នុងដាក់ឱ្យអនុវត្ត ដែលប្រការនេះទាមទារឱ្យមានការសិក្សាបន្ថែមទៀត។ ផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់បញ្ចូលសម្រាប់អនុវត្តក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ដោយឡែកចំពោះផែនការថវិការបស់រដ្ឋបាលឃុំ សង្កាត់ នៅមានភាពយឺតយ៉ាវក្នុងការដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ដោយសារការរៀបចំគម្រោងថវិកាមិនទាន់ពេលវេលា។

## ខ. ទិសដៅឆ្នាំ២០២៥

គោលបំណងនៅឆ្នាំ២០២៥ គឺជាការពង្រឹងភាពគ្រប់ជ្រុងជ្រោយនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាបណ្តើរៗ តាមរយៈការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ដើម្បីសម្រេចបានកិច្ចការនេះ គឺត្រូវធ្វើឱ្យមានសង្គតិភាពគ្នារវាងផែនការថវិកាប្រចាំឆ្នាំជាមួយនឹងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នឹងត្រូវធ្វើការសម្របសម្រួលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីឱ្យផែនការថវិកាមានការផ្សារ-

ភ្ជាប់ទៅនឹងគោលបំណងគោលនយោបាយ/កម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ដំណើរការនេះអាចសម្រេចបានតាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលបានបង្កើតឡើងសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដូចដែលបានរៀបរាប់ខាងលើ។

ការរៀបចំផែនការថវិកានឹងត្រូវផ្អែកលើមូលដ្ឋានព័ត៌មានលទ្ធផលនៃការអនុវត្តឆ្នាំមុន បែបបទ និងនីតិវិធីដែលបានកំណត់ និងគោលការណ៍ចំណាយចាំបាច់ ជាពិសេស ត្រូវមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា និងត្រូវធានាឱ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និងចំណាយថវិកា ដើម្បីពង្រឹងគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានភាពគ្រប់ជ្រុងជ្រោយ និងគ្របដណ្តប់គ្រប់ប្រភពចំណូលទាំងអស់ (ថវិការដ្ឋ ឧបត្ថម្ភធន ការផ្ទេរធនធាន ថវិកាដៃគូ និងចំណូលផ្ទាល់) និងគ្រប់មុខសញ្ញាចំណាយទាំងអស់ (ចំណាយបៀវត្ស ចំណាយចរន្តមិនមែនបៀវត្ស និងចំណាយមូលធន)។ ទន្ទឹមនឹងនេះ ការរៀបចំថវិកានឹងប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង ៧ ឱ្យបានពេញលេញ ដោយដាក់បញ្ចូលទៅក្នុងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

### គ. ផែនទីចង្អុលផ្លូវ

ដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្ត **«ថវិកាព័ត៌មានសមិទ្ធកម្ម»** នៅក្រោយឆ្នាំ២០២៥ ការរៀបចំថវិកាកម្មវិធីនឹងត្រូវពង្រីកទៅគ្រប់រដ្ឋបាលខេត្តនៅឆ្នាំ២០២០ និងរាជធានីភ្នំពេញនៅឆ្នាំ២០២១។ ស្របពេលជាមួយគ្នានឹងការពង្រីកការអនុវត្តថវិកាកម្មវិធីដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់គម្រោងនឹងត្រូវដាក់ឱ្យអនុវត្តសម្រាប់រដ្ឋបាលរាជធានី ខេត្តនៅឆ្នាំ២០២១។ ដោយឡែក ចំណាត់ថ្នាក់មុខងារនឹងត្រូវធ្វើការសិក្សានៅឆ្នាំ២០២០ ដើម្បីពិនិត្យលទ្ធភាពដាក់ឱ្យអនុវត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ក្នុងគោលដៅពង្រឹងការរៀបចំថវិកាប្រចាំឆ្នាំ ការរៀបចំ និងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) សម្រាប់រដ្ឋបាលរាជធានី ខេត្តនឹងត្រូវចាប់ផ្តើមពីឆ្នាំ២០២២តទៅ។

## ៤.១.៣. ការចរចាថវិកា និងការអនុម័តថវិកា

### ក. ការអនុវត្តបច្ចុប្បន្ន

ទោះបីជាការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត ជួបប្រសព្វគ្នានៅកម្រិតរាជធានី ខេត្ត ក៏ដំណើរការនៃការរៀបចំគម្រោងថវិកាទាំងពីរនេះធ្វើឡើងតាមដំណើរការពីរផ្សេងគ្នា។ គម្រោងថវិការបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈក្រសួងស្ថាប័នសាមី។ ចំណែកថវិការដ្ឋបាល រាជធានី ខេត្តត្រូវបានរៀបចំ និងដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័ត ហើយត្រូវបញ្ជូនគម្រោងថវិកានេះទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីចរចានិងយល់ព្រម និងបូកសរុបដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ គម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក គឺមានភាពខុសប្លែកពីរដ្ឋបាលរាជធានី ខេត្ត ដោយគម្រោងថវិកាក្រុង ស្រុកត្រូវបានពិនិត្យ និង

អនុម័តដោយក្រុមប្រឹក្សា រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបូកសរុប មុននឹងបញ្ជូនទៅរដ្ឋបាលរាជ-ធានី ខេត្ត ដើម្បីពិនិត្យនិងផ្តល់អនុលោមភាព។ ចំពោះរដ្ឋបាលឃុំ សង្កាត់វិញ ត្រូវរៀបចំគម្រោងថវិកា រួចដាក់ជូនក្រុមប្រឹក្សាខ្លួនពិនិត្យនិងអនុម័ត បន្ទាប់មកបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យនិងផ្តល់អនុលោមភាព។ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តជាកញ្ចប់ដោយស្ថាប័ននីតិប្បញ្ញត្តិ ដែលជាផ្នែកមួយនៃថវិកាជាតិ។ ដំណើរការចរចាថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនទាន់បានយកគម្រោងថវិកាតាមកម្មវិធីមកជាមូលដ្ឋានសម្រាប់ការពិភាក្សាថវិកាទេ។

ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរជំនាញរាជធានី ខេត្ត មានដំណើរការ និងផ្អែកលើការផ្សារភ្ជាប់ផ្សេងៗគ្នា។ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តត្រូវបានពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាសាមី រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាសាមី រួចបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលឃុំ សង្កាត់ គឺមិនតម្រូវឱ្យមានផែនការលទ្ធកម្មប្រចាំឆ្នាំឡើយ។ ចំណែកផែនការលទ្ធកម្មប្រចាំឆ្នាំរបស់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវបញ្ជូនទៅក្រសួងស្ថាប័នសាមី ដើម្បីដាក់បញ្ចូលក្នុងឧបសម្ព័ន្ធរួម រួចផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ផ្អែកលើផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងតួលេខកញ្ចប់ថវិកាប្រចាំឆ្នាំរៀងៗខ្លួន។

តាមនីតិវិធីបច្ចុប្បន្ន ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានរៀបចំនិងអនុម័ត ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា នៅក្រោយកិច្ចចរចាថវិកាប្រចាំឆ្នាំ។ អង្គភាពលទ្ធកម្មនៃរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនមិនបានបញ្ចប់សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំតាមពេលវេលាកំណត់ ដែលនាំឱ្យការអនុវត្តចំណាយតាមនីតិវិធីលទ្ធកម្មមិនទាន់ពេលវេលា និងមានប្រសិទ្ធភាព។

### ខ. ទិសដៅឆ្នាំ២០២៥

នៅពេលដែលការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រោមជាតិក្លាយជាផែនការរួមរបស់រាជធានី ខេត្ត តាមរយៈការធ្វើសមាហរណកម្មបញ្ចូលគ្នានូវផែនការយុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើការតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត ការពិនិត្យ និងសម្របសម្រួលដោយរដ្ឋបាលរាជធានី ខេត្ត លើគម្រោងថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជាការចាំបាច់ ដើម្បីធានាបាននូវសង្គតិភាព និងប្រសិទ្ធភាពនៃការអនុវត្តថវិកា។ រដ្ឋបាលរាជធានី ខេត្ត ចាំបាច់ត្រូវធ្វើអាទិភាវូបនីយកម្មចំណាយក្នុងអំឡុងពេលនៃការធ្វើការពិនិត្យ និងសម្របសម្រួល ដើម្បីសន្សំសំចៃថវិកា និងឆ្លើយតបទៅនឹងអាទិភាពនៅក្នុងមូលដ្ឋានឱ្យបានកាន់តែប្រសើរឡើង។ ដំណើរការនៃការចរចាថវិការដ្ឋបាលរាជធានី ខេត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលផ្អែកលើធាតុចូលបច្ចុប្បន្ននឹងត្រូវផ្លាស់ប្តូរជាបណ្តើរៗឆ្ពោះទៅរកការចរចាថវិកាតាមកម្មវិធី ដើម្បីប្រើប្រាស់ថវិកាឱ្យកាន់តែច្បាស់លាស់ និងមានប្រសិទ្ធភាពជាងមុន។

ការចរចាថវិកា ដែលបច្ចុប្បន្នផ្តោតទៅលើថវិការដ្ឋបាលរាជធានី ខេត្ត នឹងត្រូវធ្វើការពង្រឹង និងតម្រង់ទិសការចរចាថវិកាផ្តោតលើគោលនយោបាយ និងវិស័យជាអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ដែលរួមមានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ក្នុងន័យនេះ យន្តការសម្របសម្រួលមួយនៅក្នុងកម្រិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងត្រូវបង្កើតឡើង។ ទន្ទឹមគ្នានេះ គោលការណ៍ណែនាំស្តីពីការចរចាថវិកាថ្នាក់ក្រោមជាតិនឹងត្រូវរៀបចំឡើង ជាមូលដ្ឋានសម្រាប់ការចរចាថវិកាប្រចាំឆ្នាំ ស្របតាមទិសដៅនៃការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មក្រោយឆ្នាំ២០២៥។

សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ដែលកន្លងមកត្រូវបានរៀបចំ និងអនុម័តក្រោយកិច្ចចរចាថវិកា និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ត្រូវជំនួសដោយធ្វើការពិនិត្យ និងសម្រេចផែនការលទ្ធកម្មនៅក្នុងក្របខ័ណ្ឌនៃការចរចាថវិកានៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូចគ្នានេះដែរ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដាក់សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងពេលដំណាលគ្នានឹងផែនការថវិកា ដែលត្រូវដាក់ជូនអភិបាលរាជធានី ខេត្ត ដើម្បីផ្តល់អនុលោមភាព។

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំភ្ជាប់មកជាមួយនឹងសំណើគម្រោងថវិកាប្រចាំឆ្នាំដើម្បីជាមូលដ្ឋាននៃការចរចាថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ។ សេចក្តីព្រាងផែនការលទ្ធកម្មនឹងត្រូវធ្វើការកែសម្រួលឡើងវិញ ដោយផ្អែកលើលទ្ធផលនៃការចរចាថវិកា រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។ នៅពេលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួនាទីជានិយ័តករពេញលេញ ផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវពិនិត្យនិងអនុម័តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## គ. ផែនទីចង្អុលផ្លូវ

ដំណើរការនៃការចរចាថវិការដ្ឋបាលរាជធានី ខេត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបច្ចុប្បន្នផ្អែកលើធាតុចូលនឹងត្រូវធ្វើការផ្លាស់ប្តូរជាបណ្តើរៗឆ្ពោះទៅការចរចាថវិកាផ្អែកលើកម្មវិធីចាប់ពីឆ្នាំ២០២២តទៅ។ គោលការណ៍ណែនាំស្តីពីការចរចាថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវរៀបចំឡើងនៅឆ្នាំ២០២១។

សេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលត្រូវពិនិត្យ និងសម្រេចក្នុងក្របខ័ណ្ឌនៃការចរចាថវិការបស់រដ្ឋបាលរាជធានី ខេត្តជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងត្រូវអនុវត្តចាប់ពីឆ្នាំ២០១៩ តទៅ។ ចំពោះការពិនិត្យនិងអនុម័តលើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវពិនិត្យនិងអនុម័តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រឹមឆ្នាំ២០២២ ហើយចាប់ពី២០២៣តទៅ ការពិនិត្យ និងអនុម័តលើផែនការលទ្ធកម្មប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត និងមន្ទីរជំនាញរាជធានី ខេត្ត នឹងត្រូវប្រគល់សិទ្ធិជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៤.១.៤. ការអនុវត្ត និងការត្រួតពិនិត្យថវិកា

### ក. ការអនុវត្តបច្ចុប្បន្ន

#### ➢ សិទ្ធិអំណាចនៃការបញ្ជាចំណាយ

ក្នុងការអនុវត្តបច្ចុប្បន្ន រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់មានឆន្ទានុសិទ្ធិពេញលេញក្នុងការអនុវត្ត និងត្រួតពិនិត្យថវិកានៅឡើយ លើកលែងតែរដ្ឋបាលឃុំ សង្កាត់។ រដ្ឋបាលរាជធានី ខេត្ត ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន តម្រូវឱ្យស្នើសុំធានាចំណាយ និងការត្រួតពិនិត្យចំណាយ ដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែកឯរដ្ឋបាលក្រុង ស្រុក ខណ្ឌ តម្រូវឱ្យមានការត្រួតពិនិត្យចំណាយដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រោយពេលដែលច្បាប់ថវិកាប្រចាំឆ្នាំចូលជាធរមាន និងសៀវភៅថវិកាប្រចាំឆ្នាំត្រូវបានដាក់ឱ្យអនុវត្ត រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់ ដែលមិនអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន។ ដោយឡែកចំពោះមុខសញ្ញាចំណាយប្រតិបត្តិការប្រក្រតីផ្សេងៗទៀត ត្រូវបានអនុវត្តចំណាយតាមនីតិវិធីនៃការផ្តល់ធានាចំណាយ និងនីតិវិធីលទ្ធកម្មសាធារណៈ ។ យន្តការគ្រប់គ្រង និងនីតិវិធីអនុវត្តនៃការបញ្ជាចំណាយសម្រាប់រដ្ឋបាលរាជធានីខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺដូចគ្នាទៅនឹងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ដែលមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវលើការត្រួតពិនិត្យ ផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ ហើយរតនាគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈ ត្រួតពិនិត្យ និងទូទាត់ចំណាយថវិកា។ ដោយឡែក ថវិការដ្ឋបាលឃុំ សង្កាត់មិនតម្រូវឱ្យមានការធានាចំណាយទេ។

#### ➢ ការត្រួតពិនិត្យការអនុវត្តថវិកា

ការត្រួតពិនិត្យចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តតាមយន្តការមជ្ឈការទាំងក្នុងដំណាក់-កាលធានាចំណាយ កិច្ចលទ្ធកម្ម អាណត្តិកិច្ច និងការទូទាត់ លើកលែងតែថវិការដ្ឋបាលឃុំ សង្កាត់។ ការត្រួតពិនិត្យថវិកាត្រូវបានអនុវត្តដូចនៅថ្នាក់ជាតិដែរ ដែលមកទល់ពេលនេះការត្រួតពិនិត្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុវត្តដោយផ្អែកលើអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល និងអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យករសាធារណៈ។ ការធ្វើនិយ័តកម្មថវិការបស់រដ្ឋបាលរាជធានី ខេត្តនៅមិនទាន់មានភាពទន់ភ្លន់ លើកលែងតែរដ្ឋបាលខេត្តដែលអនុវត្តថវិកាកម្មវិធី។

#### ➢ កិច្ចលទ្ធកម្ម

ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅមិនទាន់បានផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានពេញ-លេញដល់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដែលជាស្ថាប័នអនុវត្តកិច្ចលទ្ធកម្មផ្ទាល់នៅឡើយ។ ការត្រួតពិនិត្យកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានអនុវត្តតាមយន្តការមជ្ឈការ ដែលមានក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុដើរតួសំខាន់ ទាំងក្នុងដំណាក់កាលរៀបចំផែនការលទ្ធកម្ម និងការត្រួតពិនិត្យកិច្ចលទ្ធកម្ម។ ដូចគ្នានេះដែរ ការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានត្រួតពិនិត្យដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

លិខិតបទដ្ឋានគតិយុត្តនាពេលបច្ចុប្បន្ន បានប្រគល់សិទ្ធិអំណាចពេញលេញដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពិនិត្យ និងសម្រេចលើការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។ តែទោះជាយ៉ាងនេះក្ដី ក្នុងការអនុវត្តជាក់ស្ដែង សិទ្ធិសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តកិច្ចលទ្ធកម្មនៅមានភាពមិនច្បាស់លាស់នៅឡើយ។

➢ **សវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ**

សវនកម្មផ្ទៃក្នុងដែលជាសេនាធិការរបស់អាណាប័កដើមខ្សែ មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា ព្រមទាំងអាចផ្ដល់យោបល់ ឬអនុសាសន៍ចាំបាច់ជូនអាណាប័កដើម្បីពិនិត្យនិងសម្រេច ឬផ្ដល់ការណែនាំ។ នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្តត្រូវកំណត់ និងអនុវត្តដោយសវនកម្មផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃ ទោះបីរដ្ឋបាលរាជធានី ខេត្តក្លាយជាអណាប័កដើមខ្សែនៃអង្គភាពថវិការបស់ខ្លួនក៏ដោយ។ ក្រៅពីមានសវនកម្មផ្ទៃក្នុង ក៏នៅមានអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្រៅ ដែលមានភារកិច្ចត្រួតពិនិត្យ វាយតម្លៃការអនុវត្តថវិកា និងផ្ដល់អនុសាសន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធ ដើម្បីចាត់វិធានការតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ខ. ទិសដៅឆ្នាំ២០២៥

➢ **សិទ្ធិអំណាចនៃការបញ្ជាចំណាយ**

កត្តាគន្លឹះនៃភាពជោគជ័យនៃប្រព័ន្ធថវិកាកម្មវិធី គឺការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅដល់អ្នកគ្រប់គ្រងផ្ទាល់ក្នុងការចាត់ចែងធនធានឱ្យបានល្អ ដើម្បីសម្រេចសមិទ្ធផល។ នៅពេលច្បាប់ថវិកាត្រូវបានអនុម័តរួច ឥណទានថវិកានឹងក្លាយជាមូលដ្ឋានក្នុងការផ្ដល់ការអនុញ្ញាតឱ្យបញ្ជាចំណាយពេញមួយឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ និង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការអនុញ្ញាតឱ្យបញ្ជាចំណាយនឹងត្រូវធ្វើឡើងជាកម្មវិធីចំណាយប្រចាំត្រីមាស/ឆមាស ស្របតាមគោលការណ៍កំណត់ដោយធ្វើការបែងចែកធនធានទៅតាមកម្មវិធី អង្គភាពថវិកា មុខចំណាយ និងពេលវេលា។ នីតិវិធីនៃការអនុវត្តថវិកានឹងត្រូវបានធ្វើទំនើបកម្ម និងពន្លឿនថែមទៀត តាមរយៈការលើកកម្ពស់ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក នឹងទទួលខុសត្រូវ និងមានគណនេយ្យភាពទាំងស្រុងចំពោះការអនុវត្ត និងត្រួតពិនិត្យហិរញ្ញវត្ថុ។ រដ្ឋបាលខណ្ឌ នៅតែជាអង្គភាពថវិកាដែលជាអាណាបក័ផ្ទេរសិទ្ធនៃថវិការាជធានីភ្នំពេញ ប៉ុន្តែសិទ្ធិអំណាចនឹងត្រូវបានគិតគូរផ្ដល់ជូនបន្ថែមទៀតក្នុងការវិភាជថវិកា និងអនុវត្តថវិកាក្នុងឋានៈជាអង្គភាពថវិកានៃរដ្ឋបាលរាជធានីភ្នំពេញ។ ចំពោះការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់ចាំបាច់ត្រូវធ្វើការគិតគូរឡើងវិញនូវយន្តការនៃការសម្របសម្រួលនានា ដែលរួមទាំងការពិនិត្យ និងការកែសម្រួលលក្ខខណ្ឌ

វិនិច្ឆ័យ ការវិភាជថវិកា ការគ្រប់គ្រង និងការត្រួតពិនិត្យវាយតម្លៃការអនុវត្តមូលនិធិឃុំ សង្កាត់ និងនីតិវិធីលទ្ធកម្មសាធារណៈ ដើម្បីធានាបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការអនុវត្តថវិកាប្រកប ដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងតម្រូវការខ្ពស់នៃការផ្តល់សេវាសាធារណៈ។

> **ការត្រួតពិនិត្យការអនុវត្តថវិកា**

ដើម្បីបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវពន្លឿន និងធ្វើសាមញ្ញកម្មការអនុវត្តថវិកា ដោយត្រូវប្រគល់សិទ្ធិជាអតិបរមាតាមការវិវត្តនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ស្របតាមទិសដៅនេះ យន្តការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត និងថវិកាមន្ទីរជំនាញរាជធានី ខេត្តដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ដែលប្រមូលផ្តុំនូវមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្ម, នឹងត្រូវទទួលបាននូវប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវផ្ទាល់កាន់តែច្រើនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនឹងមុខងារត្រួតពិនិត្យផ្នែកចំណាយ សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនឹងត្រូវលើកកម្ពស់ថែមទៀត។

ដូចគ្នានឹងថវិកាថ្នាក់ជាតិដែរ ផ្អែកតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ មុខងារគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្តនឹងត្រូវបន្តអនុវត្តយន្តការដូចបច្ចុប្បន្នក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាស្របតាមវិធានគណនេយ្យសាធារណៈ និងការគ្រប់គ្រងសាច់ប្រាក់ ប៉ុន្តែត្រូវកាត់បន្ថយការត្រួតពិនិត្យឱ្យមកនៅត្រឹមកម្រិតអប្បបរមាតាមរយៈការរៀបចំតតិយុត្តឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាពព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធ FMIS និង E-Transfer។ នាពេលខាងមុខ នៅពេលប្រព័ន្ធគ្រប់គ្រងថវិកាកាន់តែត្រូវបានកែលម្អស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងសមត្ថភាពនៃស្ថាប័នពាក់ព័ន្ធកាន់តែខ្ពស់ មុខងារគណនេយ្យករសាធារណៈនៃរតនាគាររាជធានី ខេត្តអាចនឹងត្រូវធ្វើសមាហរណកម្មជាមួយនឹងមុខងារត្រួតពិនិត្យថវិកានៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យយន្តការត្រួតពិនិត្យមានលក្ខណៈកាន់តែមានប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយ ដែលជាបុរេលក្ខខណ្ឌសម្រាប់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានគណនេយ្យភាពពេញលេញ ទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកសមិទ្ធកម្ម។

ចំពោះថវិការដ្ឋបាលក្រុង ស្រុក និងថវិការដ្ឋបាលឃុំ សង្កាត់ ការត្រួតពិនិត្យការអនុវត្តថវិកាត្រូវធ្វើតាមរយៈរតនាគាររាជធានី ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ។ លើសពីនេះ ក្នុងគោលបំណងពន្លឿន និងសម្រួលដល់ការអនុវត្តថវិកា ជាពិសេសដើម្បីផ្តល់សេវាទូទាត់ឱ្យបានឆាប់រហ័ស គណនេយ្យករសាធារណៈអាចនឹងត្រូវដាក់ឱ្យនៅអមរដ្ឋបាល ក្រុង ស្រុក ដោយអាចពង្រីកជាជំហានៗទៅតាមលទ្ធភាព និងតាមការចាំបាច់ជាក់ស្តែង។ ការអនុវត្តថវិការដ្ឋបាល ក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ជាកម្មវត្ថុនៃការត្រួតពិនិត្យក្រោយចំណាយ។ ចំណែកថវិការដ្ឋបាលខណ្ឌវិញ ដែលជាថវិកាចំណុះរាជធានីភ្នំពេញ ត្រូវអនុវត្តដូចបច្ចុប្បន្ន ដែលមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកត្រួតពិនិត្យការអនុវត្តថវិកា និងរតនាគាររាជធានីជាគណនេយ្យករសាធារណៈ។

ការស្នើសុំធ្វើនិយ័តកម្មថវិកាសម្រាប់ថវិការដ្ឋបាលរាជធានី ខេត្ត នៅតែអនុវត្តតាមយន្តការដដែល ដោយត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក៏ប៉ុន្តែ ក្រោយពេលរដ្ឋបាលរាជធានី ខេត្តអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០២១, ការផ្តល់ប្រតិភូកម្មអំណាចក្នុងការធ្វើនិយ័តកម្មឥណទានថវិកាដល់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវអនុវត្តក្នុងកម្រិតណាមួយសមស្រប។

- **កិច្ចលទ្ធកម្ម**

ក្នុងគោលបំណងពន្លឿន និងសម្រួលនីតិវិធីការងារ ការប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មនឹងត្រូវបង្កើនជាបណ្តើរៗបន្ថែមទៀតជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញនៅឆ្នាំ២០២៥ នៅពេលមានក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់។ ការប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជូនរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ នឹងត្រូវអនុវត្តជាបណ្តើរៗតាមរយៈការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច លើកលែងតែមុខចំណាយមួយចំនួនដែលមានទំហំធំ មានចរិតជាយុទ្ធសាស្ត្រ មានលក្ខណៈបច្ចេកទេសដោយឡែកសម្រាប់ការគ្រប់គ្រងនិង/ឬមានវេទយិតភាពខ្ពស់ ដែលចាំបាច់ត្រូវតែជាកម្មវត្ថុនៃការស្នើសុំការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ នឹងត្រូវពង្រឹងជាបណ្តើរៗតាមរយៈការធ្វើសវនកម្មកិច្ចលទ្ធកម្ម ព្រមទាំងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌចំពោះការរំលោភបំពានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងត្រូវទទួលបានសិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញក្នុងការពិនិត្យ និងសម្រេចលើការអនុវត្តកិច្ចលទ្ធកម្មពីក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាឱ្យបាននូវតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

ទន្ទឹមនឹងការផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោម-ជាតិ ចាំបាច់ត្រូវធ្វើការពង្រឹងការគ្រប់គ្រងការអនុវត្តកិច្ចលទ្ធកម្ម និងការធ្វើសវនកម្មកិច្ចលទ្ធកម្ម ដើម្បីធានាតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង ព្រមទាំងធានាបាននូវតម្លៃសាច់ប្រាក់ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

- **សវនកម្ម និង អធិការកិច្ចហិរញ្ញវត្ថុ**

ដើម្បីធានាប្រតិតុល្យការ តួនាទី និងភារកិច្ចអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចាំបាច់ត្រូវលើកកម្ពស់បន្ថែមទៀត។ ទោះយ៉ាងនេះក្តី ដើម្បីធានាប្រសិទ្ធភាព និងភាពសន្សំសំចៃខ្ពស់ ការងារអធិការកិច្ចហិរញ្ញវត្ថុនឹងត្រូវកំណត់ឱ្យធ្វើត្រឹមកម្រិតអប្បបរមាដោយឈរលើមូលដ្ឋាននៃភាពចាំបាច់ជាក់ស្តែង ការរាយ-ការណ៍ដោយគណនេយ្យករសាធារណៈ និងការប្តឹងផ្តល់ឬព័ត៌មាននៃភាពមិនប្រក្រតីជាយថាហេតុ។ ក្របខ័ណ្ឌ និងនីតិវិធីលម្អិតនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវកំណត់ដោយឡែក។ នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុង នឹងត្រូវរៀបចំឡើងដោយត្រូវមានការពិគ្រោះរួមគ្នារវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

### គ. ផែនទីចង្អុលផ្លូវ

កត្តាគន្លឹះនៃភាពជោគជ័យនៃប្រព័ន្ធថវិកាកម្មវិធី គឺការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅដល់អ្នកគ្រប់គ្រងផ្ទាល់ក្នុងការចាត់ចែងធនធានឱ្យបានល្អដើម្បីសម្រេចសមិទ្ធផល។ តាមទិសដៅនេះ ការផ្តល់ការធានាចំណាយ និងការទូទាត់នឹងត្រូវពន្លឿន និងលើកកម្ពស់ប្រសិទ្ធភាពតាមរយៈការសម្រួលនីតិវិធីការងារ និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំនួសឱ្យការប្រើប្រាស់ក្រដាសស្នាមយ៉ាងយូរត្រឹមឆ្នាំ២០២៥។ ការផ្ទេរឥណទាន ឬនិយ័តកម្មឥណទានថវិកានឹងត្រូវចាប់ផ្តើមធ្វើប្រតិភូកម្មអំណាចជាបណ្តើរៗកាន់តែច្រើនជាងមុនដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាប់ពីឆ្នាំ២០២១។

យន្តការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដែលត្រូវធ្វើតាមរយៈរតនាគាររាជធានី ខេត្តក្នុងមុខងារជាគណនេយ្យករសាធារណៈ ដែលត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវចាប់ផ្តើមរៀបចំដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២២។ គោលការណ៍ណែនាំស្តីពីនីតិវិធីចំណាយ និងបែបបទនៃការត្រួតពិនិត្យហិរញ្ញវត្ថុដែលមានបច្ចុប្បន្ន ជាពិសេស អនុក្រឹត្យលេខ៨១ និងអនុក្រឹត្យលេខ៨២ ព្រមទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានានឹងត្រូវកែលម្អឡើងវិញ ស្របតាមពេលវេលា និងទិសដៅដែលបានចែងក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវទទួលបាននូវប្រតិភូកម្មសិទ្ធិអំណាច និងការទទួលខុសត្រូវផ្ទាល់កាន់តែច្រើនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការអនុវត្តកិច្ចលទ្ធកម្មចាប់ពីឆ្នាំ២០១៩ រហូតដល់មានការប្រគល់សិទ្ធិសម្រេចពេញលេញនៅឆ្នាំ២០២៥។ រដ្ឋបាលរាជធានី ខេត្ត នឹងទទួលបានសិទ្ធិសម្រេចពេញលេញក្នុងការអនុវត្តកិច្ចលទ្ធកម្មចាប់ពីឆ្នាំ២០២៥តទៅ។ ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌនឹងធ្វើឡើងតាមយន្តការមជ្ឈការដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្របខ័ណ្ឌ និងនីតិវិធីលម្អិតនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ នឹងត្រូវកំណត់ឱ្យបានច្បាស់លាស់នៅឆ្នាំ២០២០។ នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងរបស់អង្គភាពថវិកានៅរដ្ឋបាលរាជធានី ខេត្តនឹងត្រូវកំណត់ឱ្យបានច្បាស់លាស់ចាប់ពីឆ្នាំ២០២១។

## ៤.១.៥. ប្រព័ន្ធរបាយការណ៍, ការតាមដាន និង ការវាយតម្លៃថវិកា

### ក. ការអនុវត្តបច្ចុប្បន្ន

ការរៀបចំរបាយការណ៍ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៅមានភាពយឺតយ៉ាវ ហើយគុណភាពរបាយការណ៍ក៏មិនទាន់អាចក្លាយជាឧបករណ៍សម្រាប់ផ្តល់ព័ត៌មាន និងសម្រាប់ធ្វើជាមូលដ្ឋានវាយតម្លៃលទ្ធផលសម្រេចបានទាំងទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពគោលនយោបាយ/យុទ្ធសាស្ត្ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានទាំងស្រុងឡើយ។

## ខ. ទិសដៅឆ្នាំ២០២៥

តាមទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដូចបានលើកឡើងនៅក្នុងផ្នែកទី៣ ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងក្លាយជាផែនការដែលធ្វើសមាហរណកម្មនូវគ្រប់ប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូចនេះ របបរបាយការណ៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវធ្វើស្ថាប័ននីយកម្មជាបណ្តើរៗ ហើយសមត្ថភាពក្នុងការធ្វើរបាយការណ៍ថវិកាកម្មវិធីនឹងត្រូវពង្រឹងបន្ថែមទៀត។ ប្រព័ន្ធរបាយការណ៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានលក្ខណៈសាមញ្ញ និងសមស្របទៅតាមការទទួលខុសត្រូវជាគតិយុត្តនៅថ្នាក់ក្រោមជាតិ។

របបរបាយការណ៍នៃចង្កោមកម្មវិធីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើពីក្រោមឡើងលើ។ រដ្ឋបាលឃុំ សង្កាត់ នឹងរាយការណ៍ពីវឌ្ឍនភាពក្នុងទម្រង់ជាលទ្ធផលក្នុងឆ្នាំនៃសកម្មភាពទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរាយការណ៍ពីវឌ្ឍនភាពនៃអនុកម្មវិធីទៅឱ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍បូកសរុបទាំងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលនៅកម្រិតកម្មវិធី អនុកម្មវិធី និងរាយការណ៍ទៅក្រុមប្រឹក្សារាជធានី ខេត្ត និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទម្រង់នៃរបាយការណ៍ នឹងត្រូវកែសម្រួលជាជំហានៗ ដើម្បីបំពេញទៅតាមការតម្រូវរបស់ក្រុមប្រឹក្សារាជធានី ខេត្តផង និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផង។

សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការវាយតម្លៃថវិកានៅមានកម្រិត ដូចនេះ រដ្ឋបាលថ្នាក់-ក្រោមជាតិ នឹងត្រូវអនុវត្តត្រឹមការតាមដានថវិកា និងការធ្វើរបាយការណ៍ថវិកា។ នៅពេលដែលប្រព័ន្ធតាមដាន និងរបាយការណ៍ថវិកាអនុវត្តបានល្អហើយ ប្រព័ន្ធវាយតម្លៃថវិកានឹងចាប់ផ្តើមដាក់ឱ្យអនុវត្តសាកល្បងជាបណ្តើរៗ ។

ការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តតាមទិសដៅវិមជ្ឈការ ដោយត្រូវផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ក្នុងន័យនេះ ចាំបាច់ត្រូវបង្កើតឱ្យមានយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មឱ្យបានជាទៀងទាត់ និងប្រកបដោយប្រសិទ្ធភាព។ រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ មកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបូកសរុប រួចបញ្ជូនបន្តមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំណែក មន្ទីរជំនាញរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំមកក្រសួងស្ថាប័នសាមីដើម្បីបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## គ. ផែនទីចង្អុលផ្លូវ

ការធ្វើរបាយការណ៍ និងការតាមដានការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវពិនិត្យមើលឡើងវិញដើម្បីរៀបចំបង្កើតឱ្យមានក្របខ័ណ្ឌ និងនីតិវិធីច្បាស់លាស់មួយសម្រាប់របាយការណ៍ផ្នែកហិរញ្ញវត្ថុ និងផ្នែកលទ្ធផល ។ គោលការណ៍ណែនាំស្តីពីនីតិវិធីនៃការរៀបចំរបាយការណ៍ និងការតាមដានការអនុវត្តថវិកានឹងត្រូវរៀបចំចាប់ពីឆ្នាំ២០១៩ ហើយដាក់ឱ្យអនុវត្តនៅឆ្នាំ២០២០។

សម្រាប់គោលដៅនៅឆ្នាំ២០២៥ រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តត្រឹមការតាមដានថវិកា និងការធ្វើរបាយការណ៍ថវិកា។ ដោយឡែក នៅពេលដែលប្រព័ន្ធតាមដាន និងរបាយការណ៍ថវិកាអនុវត្តបានល្អហើយ, ប្រព័ន្ធវាយតម្លៃថវិកា នឹងចាប់ផ្តើមដាក់ឱ្យអនុវត្តសាកល្បងជាបណ្តើរៗក្រោយឆ្នាំ២០២៥ តទៅ។

## ៤.២. ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់

### ៤.២.១. ក្របខ័ណ្ឌគតិយុត្តនៃថវិកា

ក្រៅពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ នៅមានលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ត្រូវបានដាក់ឱ្យអនុវត្តសម្រាប់ការរៀបចំ និងអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត។ លិខិតបទដ្ឋានគតិយុត្តទាំងនោះ ទោះបីជាត្រូវបានរៀបចំឡើងក្នុងគោលដៅ និងគោលបំណងរួម ដើម្បីឆ្លើយតបបានទៅនឹងគោលការណ៍ និងវិធានដែលបានកំណត់ដោយច្បាប់ទាំងពីរនេះក៏ដោយ ក៏លិខិតបទដ្ឋានគតិយុត្តិទាំងនោះត្រូវបានរៀបចំឡើងដាច់ដោយឡែកៗពីគ្នា។

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ ក្នុងន័យនេះ ក្រោយពេលដែលច្បាប់នេះត្រូវបានធ្វើវិសោធនកម្មច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ ក៏ចាំបាច់ត្រូវពិនិត្យ និងកែសម្រួលឡើងវិញដើម្បីធានាបាននូវសង្គតិភាពជាមួយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨។ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ ត្រូវធ្វើការពិនិត្យ និងរៀបចំប្រមូលផ្តុំឡើងវិញ ព្រមទាំងធ្វើសុខដុមនីយកម្មលិខិតបទដ្ឋានគតិយុត្តិទាំងនោះក្នុងគោលបំណងធានាឱ្យមានលិខិតបទដ្ឋានគតិយុត្តរួមតែមួយ ដែលរួមបញ្ចូលនូវគោលការណ៍ វិធាន និងនីតិវិធីពាក់ព័ន្ធនានា ដែលអាចអនុវត្តបានដោយគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្របទៅតាមចរិតលក្ខណៈនៃរចនាសម្ព័ន្ធគ្រប់គ្រង សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

គោលដៅនៅឆ្នាំ២០២៥ គឺច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១១ ត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ ក្រោយពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត។ កិច្ចការនេះនឹងត្រូវចាប់ផ្តើមនៅឆ្នាំ២០២០ និងបញ្ចប់នៅឆ្នាំ២០២២។ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើការពិនិត្យ និងរៀបចំប្រមូលផ្តុំឡើងវិញ ព្រមទាំងធ្វើសុខដុមនីយកម្មលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដោយត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ២០២៣ និងបញ្ចប់នៅឆ្នាំ២០២៥។

### ៤.២.២. ការកសាង និង អភិវឌ្ឍសមត្ថភាព

ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានដល់ដំណាក់កាលទី៣ ដែលផ្តោតទៅលើការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ហើយភាពជាម្ចាស់ និងការទទួលខុសត្រូវភាគច្រើនត្រូវបានផ្ទេរទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការដាក់ឱ្យរដ្ឋបាលរាជធានី ខេត្តអនុវត្តថវិកាកម្មវិធីជាបណ្តើរៗ ដែលជាជំហានមួយនៅលើទិសដៅឆ្ពោះទៅរកប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្ម និងវិមជ្ឈការ។ ជាមួយគ្នានេះដែរ គោលដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺការបង្កើនធនធានថវិកាកាន់តែច្រើនឡើងទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់ទៅនឹងការកសាងសមត្ថភាព និងក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់។

ដើម្បីសម្រេចបានគោលដៅនៃការធ្វើទំនើបកម្ម និងការពង្រឹងប្រព័ន្ធថវិកា ជាពិសេសការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត គឺចាំបាច់ត្រូវឱ្យមានការកសាង និងអភិវឌ្ឍសមត្ថភាពដល់អ្នកអនុវត្តផ្ទាល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកសាងសមត្ថភាពមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងចាប់ផ្តើមនៅឆ្នាំ២០១៩ និងមន្ត្រីជំនួយការឃុំ សង្កាត់ទទួលបន្ទុកហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់ នឹងទទួលការបណ្តុះបណ្តាលចាប់ផ្តើមនៅឆ្នាំ២០២០។

### ៤.២.៣. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

ការអនុវត្តប្រព័ន្ធ FMIS នឹងជួយកែលម្អការរៀបចំ និងការអនុវត្តថវិកាថ្នាក់ក្រោមជាតិ តាមរយៈការពន្លឿន និងធ្វើស្វ័យប្រវត្តិកម្មការទូទាត់ ការកត់ត្រាគណនេយ្យ និងការរៀបចំរបាយការណ៍។ ជាក់ស្តែង ប្រព័ន្ធ FMIS ត្រូវបានពង្រីកដាក់ឱ្យអនុវត្តដល់គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត។ ដើម្បីឱ្យប្រព័ន្ធ FMIS ក្លាយជាឧបករណ៍សំខាន់សម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ប្រព័ន្ធ FMIS នឹងត្រូវដាក់ឱ្យអនុវត្តនៅគ្រប់រដ្ឋបាលរាជធានី ខេត្តនៅឆ្នាំ២០២២។

៙៙✵៙៙

# ៥. សេចក្ដីសន្និដ្ឋាន

ចាប់តាំងពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០០៤ មក រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ជាពិសេស សម្រេចបានជាសារវន្តនូវជំហានទី១គឺ *ការបង្កើនភាពជឿទុកចិត្តនៃថវិកា (២០០៥-២០០៨)* និងជំហានទី២គឺ *ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (២០០៩-២០១៥)* ។ បច្ចុប្បន្ននេះ ការអនុវត្តជំហានទី៣គឺ *ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ* ក៏កំពុងមានវឌ្ឍនភាពល្អ ដោយបានចាប់ផ្ដើមនៅឆ្នាំ២០១៦ ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២០ មុននឹងឈានទៅអនុវត្តជំហានទី៤គឺ *ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម* ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។ សមិទ្ធផលទាំងនេះអាចសម្រេចទៅបានដោយមានការចូលរួមយ៉ាងសកម្ម និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ និងការគាំទ្រដ៏ខ្លាំងក្លាពីថ្នាក់ដឹកនាំ ក៏ដូចជាស្ថាបនិកគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា។

គោលដៅស្នូលសំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការកែទម្រង់ប្រព័ន្ធថវិកាដែលជាលក្ខខណ្ឌចាំបាច់ និងមិនអាចខ្វះបាន ដើម្បីពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងចំណូល និងចំណាយថវិកាជាតិ ដែលរួមមានការវិភាជថវិកា និងការប្រើប្រាស់ថវិកាសម្រាប់ជាគុណ-ប្រយោជន៍ដល់ការគាំទ្រដំណើរការអនុវត្តគោលនយោបាយតាមវិស័យ និងគោលបំណងគោលនយោបាយ ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍ជាតិ។

រដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើការកែទម្រង់ប្រព័ន្ធថវិកាជាបណ្ដើរៗ ពីការអនុវត្តថវិកាផ្អែកលើធាតុចូលទៅការអនុវត្តថវិកាផ្អែកតាមកម្មវិធី ដែលអាចវាស់វែងលទ្ធផលសម្រេចបាន ស្របតាមទិសដៅជាយុទ្ធសាស្ត្រនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្មនៅឆ្នាំ២០២៥។ បើធៀបនឹងថ្នាក់ជាតិ ការអនុវត្តកម្មវិធីកែទម្រង់នេះ មានភាពយឺតយ៉ាវ ដោយសារវាជាការងារកែទម្រង់ថ្មីជាមួយនឹងសមត្ថភាពរបស់មន្ត្រីនៅមានកម្រិតដែលទាមទារពេលវេលាច្រើនក្នុងការសិក្សាឈ្វេងយល់ពីទស្សនៈ ចំណេះដឹងថ្មីៗ និងបទពិសោធន៍ជាអន្តរជាតិ ដើម្បីអាចកំណត់បាននូវចក្ខុវិស័យឱ្យកាន់តែច្បាស់លាស់ស្របទៅនឹងគោលនយោបាយអាទិភាពជាតិ។

ទោះយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តក្នុងការពន្លឿនការងារកែទម្រង់ប្រព័ន្ធថវិការដ្ឋបាល-ថ្នាក់ក្រោមជាតិ ឱ្យស្របទៅនឹងការងារកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ។ ជាក់ស្ដែង *យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥* បានផ្ដោតជាចម្បងទៅលើប្រព័ន្ធថវិកាជាតិ ព្រមជាមួយនឹងការផ្ដល់នូវគោលការណ៍ និងមគ្គុទ្ទេសក៍សម្រាប់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រនេះ បានសម្រេចជ្រើសរើសយក **«ថវិកាព័ត៌មានសមិទ្ធកម្ម»** ជាទិសដៅជាក់លាក់សម្រាប់ធ្វើការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាជំហានៗរហូតដល់ឆ្នាំ២០២៥។

ការផ្លាស់ប្ដូរការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិពីអភិក្រមផ្អែកលើធាតុចូលទៅអភិក្រមផ្អែកលើកម្មវិធីអាចនឹងសម្រេចបាន ប៉ុន្តែការផ្លាស់ប្ដូរពីប្រព័ន្ធ **«ថវិកាកម្មវិធី»** ទៅរកប្រព័ន្ធ **«ថវិកាព័ត៌មានសមិទ្ធកម្ម»**

នឹងជួបបញ្ហាប្រឈមទាំងធនធានមនុស្ស ទាំងធនធានហិរញ្ញវត្ថុ និងភាពស្មុគស្មាញនៃប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិបច្ចុប្បន្ន ដែលទាមទារឱ្យមានពេលវេលាច្រើនក្នុងការកែលម្អមុននឹងប្រព័ន្ធ **«ថវិកាព័ត៌មានសមិទ្ធកម្ម»** ត្រូវបានដាក់ឱ្យអនុវត្ត។ ការអនុវត្តថវិកាកម្មវិធី មានភាពសាមញ្ញជាង អាចអនុវត្តបាន និងគ្រប់គ្រាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ជាវិភាគទានសម្រាប់ការសម្រេចបាននូវសមិទ្ធផលជាតិ។ ដូចនេះ ការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវកំណត់ក្របខ័ណ្ឌពេលវេលាថ្មី នៅក្រោយឆ្នាំ២០២៥។ គោលដៅសម្រាប់ឆ្នាំ២០២៥នេះ គឺការពង្រឹងការអនុវត្តថវិកាកម្មវិធីជាបណ្តើរៗ ដើម្បីឈានដល់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ដើម្បីធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងអាទិភាពជាតិ ស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

*ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ២០១៩-២០២៥* បានកំណត់នូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនទីចង្អុលផ្លូវ ដោយផ្តោតលើសមាសធាតុគន្លឹះៗ ដូចខាងក្រោម÷

ទី១÷ ធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតម្រឹមជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួងស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត)។ ការធ្វើសមាហរណកម្មផែនការនិយកម្ម គឺការលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ ដើម្បីសម្រេចគោលបំណងរួមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត នឹងត្រូវកែលម្អ ដោយត្រូវផ្តល់ភាពទន់ភ្លន់ឱ្យមានការដាក់បញ្ចូលនូវអាទិភាពនៅថ្នាក់មូលដ្ឋាន ដែលជាតម្រូវការ និងសំណូមពរនានាពីរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជាអភិក្រមពីក្រោមទៅលើ។

ទី២÷ កែលម្អ និងផ្លាស់ប្តូរជាជំហានៗ វដ្តថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយត្រូវកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកា។ ការអនុវត្ត និងត្រួតពិនិត្យថវិកា នឹងត្រូវពន្លឿន និងធ្វើសាមញ្ញកម្ម ដោយប្រគល់សិទ្ធិជាអតិបរមា តាមការវិវត្តនៃការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាព និងគណនេយ្យភាព ស្របតាមទស្សនាទាននៃថវិកាព័ត៌មានសមិទ្ធកម្ម និងធ្វើទំនើបកម្មតាមរយៈការកាត់បន្ថយនីតិវិធីអនុវត្ត និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទី៣÷ ធ្វើស្ថាប័ននីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍នៅថ្នាក់ក្រោមជាតិ និងបង្កើនសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យធ្វើរបាយការណ៍លទ្ធផលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត។ ប្រព័ន្ធរបាយការណ៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានលក្ខណៈសាមញ្ញ និងសមស្របទៅតាមការទទួលខុសត្រូវជាគតិយុត្តនៅថ្នាក់ក្រោមជាតិ។

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥* ក៏បានកំណត់គោលបំណង និងគូសវាសផ្លូវនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដោយធ្វើការពន្លឿន និង កែសម្រួលនីតិវិធីលទ្ធកម្មសាធារណៈ តាមអភិក្រមជាជំហានៗ ដើម្បីឱ្យមានសង្គតិភាពជាមួយទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ជារួម *ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ -២០២៥* បានកំណត់ទិសដៅ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសង្គតិភាពជាមួយនឹងប្រព័ន្ធថវិកាជាតិ តាមអភិក្រម*សាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព* ស្របទៅតាមសមត្ថភាពនិងបរិការណ៍ជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្អែកលើផែនទីចង្អុលផ្លូវដែលមានក្របខ័ណ្ឌពេលវេលាច្បាស់លាស់ ត្រូវបានរៀបចំឡើងដោយដាក់ចេញនូវសកម្មភាពកែទម្រង់ជាក់ស្តែង តាមលំដាប់លំដោយ ដើម្បីសម្រេចបានគោលបំណងនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់នៃតួអង្គពាក់ព័ន្ធ ជាមួយនឹងការរួមវិភាគទានផ្នែកចំណេះដឹងដ៏មានតម្លៃពីដៃគូអភិវឌ្ឍ គឺជាកត្តាគន្លឹះក្នុងការធានាឱ្យបានជោគជ័យនៃការកែទម្រង់ប្រព័ន្ធថវិកា។ លើសពីនេះ ការគាំទ្រយ៉ាងមុតមាំ និងការណែនាំជាប្រចាំ ពីសំណាក់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមេបញ្ជាការតែមួយ បានធ្វើឱ្យការកែទម្រង់ហិរញ្ញវត្ថុសាធារណៈទទួលបានជោគជ័យគួរជាទីមោទនៈ និងកំពុងបន្តមានសន្ទុះទៅមុខ គឺជាកត្តាមិនអាចខ្វះបាន ដើម្បីផ្តល់ក្តីសង្ឃឹមដល់កម្ពុជាក្នុងការកែទម្រង់ប្រព័ន្ធថវិកា ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព ឆ្ពោះទៅសម្រេចគោលដៅឆ្នាំ២០២៥៕

ឧឧ✻៚៚

# ឧបសម្ព័ន្ធ

## ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រ
## នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥
## (ពង្រឹងការអនុវត្តថវិកាកម្មវិធី និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយថ្នាក់ក្រោមជាតិ)

| ល.រ | ការងារកែទម្រង់ | អង្គភាពទទួលខុសត្រូវអនុវត្ត | ចាប់ផ្ដើម | បញ្ចប់ | គោលបំណង |
|---|---|---|---|---|---|
| I. | **ផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្ត** (BSP) | | | | |
| ១. | ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១៩ | ២០២០ | • កែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធ-សាស្ត្រថវិកា<br>• រៀបចំឡើងវិញនូវរចនាសម្ព័ន្ធកម្មវិធី ដែលធានាឱ្យមានការផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>• កំណត់នូវចំនួនសូចនាករសមិទ្ធកម្ម (Performance Indicator) |
| | | ក.ស.ហ.វ | ២០២០ | ២០២០ | • ជ្រើសរើសមន្ត្រីថវិកាក្នុង GDSNAF ដើម្បីគាំទ្រដល់ការងារកែទម្រង់ |

| | | | | | |
|---|---|---|---|---|---|
| ២. | ការធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការតម្រឹមផែនការជាមួយមន្ទីរជំនាញរាជធានី ខេត្ត | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២១ | ២០២៣ | • ធ្វើសមាហរណកម្មផែនការរបស់រដ្ឋបាលរាជធានី ខេត្ត, ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់<br>• ធ្វើការតម្រឹមផែនការជាមួយមន្ទីជំនាញរាជធានី ខេត្ត |
| II. | **ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ការចរចាថវិកា និងការអនុម័តថវិកា** | | | | |
| ១. | ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១៨ | ២០២១ | • ពង្រីកការរៀបចំថវិកាកម្មវិធីទៅគ្រប់រដ្ឋបាលខេត្តនៅឆ្នាំ២០២០<br>• ដាក់បញ្ចូលរដ្ឋបាលរាជធានីអនុវត្តថវិកាកម្មវិធីនៅឆ្នាំ២០២១ |
| | | ក.ស.ហ.វ | ២០១៨ | ២០២១ | • ពង្រីកការប្រើប្រាស់ចំណាត់ថ្នាក់ និង ដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS<br>- ដាក់ឱ្យប្រើប្រាស់ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់គម្រោងនៅឆ្នាំ២០២១<br>- សិក្សាលទ្ធភាពដាក់ឱ្យអនុវត្តចំណាត់ថ្នាក់មុខងារនៅឆ្នាំ២០២០ |
| | | | ២០១៩ | ២០២២ | • រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) សម្រាប់រដ្ឋបាលរាជធានី ខេត្ត ចាប់ផ្តើមពីឆ្នាំ២០១៩ និង អនុវត្តពេញលេញនិងមានប្រសិទ្ធភាពនៅឆ្នាំ២០២១ |
| ២. | ការចរចាថវិកា និងការអនុម័តថវិកា | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២១ | ២០២២ | • រៀបចំគោលការណ៍ណែនាំស្តីពីការចរចាថវិកាកម្មវិធីនៅឆ្នាំ២០២១<br>• ធ្វើការចរចាថវិការដ្ឋបាលរាជធានី ខេត្ត ផ្អែកលើកម្មវិធីចាប់ពីឆ្នាំ២០២២ |

| | | | | | |
|---|---|---|---|---|---|
| ៣. | ការពិនិត្យ និង សម្រេចផែនការលទ្ធកម្ម | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១៩ | ២០២៣ | • ភ្ជាប់សេចក្តីព្រាងផែនការលទ្ធកម្មក្នុងពេលចរចាថវិការដ្ឋបាលរាជធានី ខេត្តនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ពីឆ្នាំ២០១៩<br>• សេចក្តីព្រាងផែនការលទ្ធកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ ផ្ញើជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របពេលដែលផែនការថវិកាត្រូវបានផ្តល់អនុលោមភាព ចាប់ពីឆ្នាំ២០១៩<br>• មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និង សម្រេចលើផែនការលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត និងមន្ទីជំនាញរាជធានី ខេត្តចាប់ពីឆ្នាំ២០២៣តទៅ |
| III. | **ការអនុវត្ត និងការត្រួតពិនិត្យថវិកា** | | | | |
| ១. | ការត្រួតពិនិត្យការអនុវត្តថវិកា | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២១ | | • និយ័តកម្មថវិកានឹងត្រូវធ្វើប្រតិភូកម្មអំណាចបណ្តើរៗកាន់តែច្រើនជាងមុនដល់រដ្ឋបាលរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ចាប់ពីឆ្នាំ២០២១ |
| | | | ២០២២ | | • ចាប់ផ្តើមសាកល្បងយន្តការត្រួតពិនិត្យការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក តាមរយៈរតនាគាររាជធានី ខេត្ត ចាប់ពីឆ្នាំ២០២២ |
| | | | ២០២៥ | ២០២៥ | • រៀបចំសិក្សាដើម្បីត្រៀមអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម សម្រាប់ការចាប់ផ្តើមអនុវត្តសាកល្បងក្រោយឆ្នាំ២០២៥ |
| ២. | ការត្រួតពិនិត្យការបើកផ្តល់ | ក.ស.ហ.វ | ២០១៩ | ២០២៥ | • កាត់បន្ថយការត្រួតពិនិត្យការបើកផ្តល់ឱ្យមកនៅត្រឹមកម្រិតអប្បបរមា តាមរយៈការរៀបចំគតិយុត្តឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាព ព្រមជាមួយនឹងការប្រើប្រាស់ប្រព័ន្ធ FMIS នៅឆ្នាំ២០២៥ |

| | | | | | |
|---|---|---|---|---|---|
| ៣. | កិច្ចលទ្ធកម្ម | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១៩ | ២០២៥ | • រដ្ឋបាលរាជធានី ខេត្ត និង រដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងត្រូវទទួលបាននូវប្រតិភូកម្មសិទ្ធិអំណាច និង ការទទួលខុសត្រូវក្នុងការអនុវត្តកិច្ចលទ្ធកម្ម ជាបណ្តើរៗចាប់ពីឆ្នាំ២០១៩តទៅ |
| | | | ២០១៩ | ២០២៣ | • ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកាន់បន្ថយជាបណ្តើរៗពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៣ |
| ៤. | អធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង | ក.ស.ហ.វ | ២០២០ | ២០២០ | • នីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវកំណត់ឱ្យបានច្បាស់លាស់នៅឆ្នាំ២០២០ |
| | | | ២០២១ | ២០២២ | • នីតិវិធីនៃការធ្វើសវនកម្មផ្ទៃក្នុងនៅរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវកំណត់ឱ្យបានច្បាស់លាស់ចាប់ពីឆ្នាំ២០២១ |
| IV. | **ប្រព័ន្ធរបាយការណ៍, ការតាមដាន និងការវាយតម្លៃថវិកា** | | | | |
| ១. | ប្រព័ន្ធរបាយការណ៍ និងការតាមដានថវិកា | ក.ស.ហ.វ | ២០១៩ | ២០២០ | • ក្របខ័ណ្ឌ និង នីតិវិធីសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងការតាមដានការអនុវត្តថវិកា នឹងត្រូវចាប់ផ្តើមរៀបចំនៅឆ្នាំ២០១៩ |
| ២. | ការវាយតម្លៃថវិកា | ក.ស.ហ.វ | ២០២៤ | ២០២៥ | • ក្របខ័ណ្ឌវាយតម្លៃថវិកា នឹងត្រូវរៀបចំចាប់ពីឆ្នាំ២០២៤ និងត្រូវដាក់ឱ្យអនុវត្តសាកល្បងចាប់ពីឆ្នាំ២០២៥ |
| V. | **ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់** | | | | |
| ១. | ក្រខ័ណ្ឌគតិយុត្តនៃថវិកា | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២០ | ២០២២ | • ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវពិនិត្យកែសម្រួលឡើងវិញ |

| | | | | | |
|---|---|---|---|---|---|
| | | | ២០២៣ | ២០២៥ | • ប្រមូលផ្តុំ និងធ្វើសុខដុមនីយកម្មលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ |
| ២. | ការកសាង និងអភិវឌ្ឍសមត្ថភាព | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២០ | ២០២១ | • បណ្តុះបណ្តាលមន្ត្រីរដ្ឋបាលរាជធានី ខេត្តស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា រាជធានី ខេត្ត |
| | | ក.ស.ហ.វ/ រដ្ឋបាលថ្នាក់ក្រោមជាតិ | ២០១៩ | ២០២០ | • រៀបចំកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់÷<br>- ការកសាងសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅឆ្នាំ២០១៩<br>- មន្ត្រីជំនួយការឃុំ សង្កាត់ នឹងទទួលការបណ្តុះបណ្តាលចាប់ផ្តើមនៅឆ្នាំ២០២០ |
| ៣. | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ក.ស.ហ.វ/ រដ្ឋបាលរាជធានី ខេត្ត | ២០១៩ | ២០២២ | • ពង្រីកការដាក់ចំណាត់ថ្នាក់ថវិកាទាំង៧ នៅក្នុងប្រព័ន្ធ FMIS |
| | | | ២០២២ | | • ដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដល់រដ្ឋបាលរាជធានី ខេត្តចាប់ពីឆ្នាំ ២០២២ |